# ស្ដាប់ចំរៀង



ភាគទី ១

ព. ស. ២៤៩៨ គ. ស. ១៩៥៥

រក្សាសិទ្ធិ

បោះពុម្ពលើកទី ២

តំលៃ ២០ រៀល

មានលក់គ្រប់បណ្ណាគារ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

៦១៤.
១៤ង

www.budinst.gov.kh www.elibraryofcambodia.org

៣៩០.០៤៩

# ទម្លាប់ទំនៀម

## ឧកញ៉ាមហាមន្ត្រី

ញ៉ុក - ថែម

រៀបរៀង

ភាគទី ១

បោះពុម្ពលើកទី ២

ព. ស. ២៤៩៨ – គ. ស. ១៩៥៥

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៧១១១/៥៦

រក្សាសិទ្ធិ

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

លេខ ៤០២៧ ប្រកាសក្រសួង

# រដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិ

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ។

បានឃើញព្រះរាជក្រឹត្យលេខ ៦១៩ ន.ស. ចុះថ្ងៃ ៣ តុលា គ.ស. ១៩៥៥ ស្ដីពីការតែងតាំងគណរដ្ឋមន្ត្រី ។

បានឃើញសេចក្ដីកត់ហេតុ ចុះថ្ងៃ ៣០ កញ្ញា គ.ស. ១៩៥៥ នៃគណកម្មការបឋមសិក្សាខ្មែរ ដែលតាំងដោយប្រកាសក្រសួងលេខ ១០៩២ ចុះថ្ងៃ ២២ មិនា គ.ស. ១៩៥៥ ។

តាមសេចក្ដីស្នើនៃអធិការនាយកបឋមសិក្សា ។

## សំរេច៖

ប្រការ ១.– សៀវភៅ "ទម្លាប់ទំនៀម" ភាគទី ១ ដែលរៀបរៀងដោយ ឯ. ឧ. ញ៉ិក-ទូវ ចាងហ្វាងព្រះរាជមន្ទីរ បានបញ្ចូលទៅក្នុងពពួកសៀវភៅទីងការផ្សាយខាងការសិក្សា ហើយដែលទីងបានសេចក្ដីអនុញ្ញាតឲ្យប្រើប្រាស់ក្នុងសាលាសាធារណៈទូទៅ ក្នុងព្រះរាជ-អាណាចក្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រការ ២.– នាយខុទ្ទកាល័យនឹងអធិការនាយកបឋមសិក្សា ត្រូវទទួលភារៈចាត់ការតាមមុខក្រសួងរៀងខ្លួន ដើម្បីនឹងឲ្យបានប្រតិបត្តិតាមប្រកាសក្រសួងនេះ ។

ភ្នំពេញនៅថ្ងៃទី ២០ ខែតុលា គ.ស. ១៩៥៥

រដ្ឋលេខាធិការក្រសួងសិក្សាធិការជាតិ

ហត្ថលេខា: ហួត-សម្បត្តិ

បានចំឡងត្រឹមត្រូវហើយ

ជួសអគ្គលេខាធិការនៃគណរដ្ឋមន្ត្រី

តាមបង្គាប់នាយការិយាល័យរបៀប | ចំឡងថែកនាយខុទ្ទកាល័យ

ហត្ថលេខា: ឈួន-ប្រឹក | ជេត-គួន

អ្នកទទួល:

- មន្ទីរព្រះរាជាយុត្តកៈ
- មន្ទីរនាយករដ្ឋមន្ត្រី
- មន្ទីរលេខាធិការស្ថានគណរដ្ឋមន្ត្រី
- មន្ទីររាជកិច្ច
- វិទ្យាល័យអនុវិទ្យាល័យទាំងអស់
- សាលាបឋមសិក្សានារីនៅព្រះរាជធានី
- អធិការបឋមសិក្សាក្នុងព្រះរាជអាណាចក្រ
- សាមីខ្លួន
- មន្ទីរស្ដីការក្រសួងសិក្សាធិការជាតិ
- ទុកឯកសារ ។

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្ដីផ្ដើម

ខ្ញុំរៀបរៀងទម្លាប់ទំនៀមនេះឡើងឲ្យត្រូវតាមប្រពៃណីស្រុករបស់យើងដែលខ្ញុំធ្លាប់បានដឹង បានឃើញ ហើយចាំទុកមកតាំងពីខ្ញុំដឹងខុសត្រូវ ។ អ្នកឧកញ៉ាមហាវិនិច្ឆ័យ (ឆៅ) ជាបិតាខ្ញុំ លោកបានហ្វឹកហ្វឺនខ្ញុំក្នុងរបៀបគារវកិច្ចជាច្រើនចំពូក ។

ដល់ខ្ញុំបានធ្វើការជាគ្រូបង្រៀន ខ្ញុំបានចូលគាល់បំរើសម្ដេចព្រះរាជអយ្យកោវរចក្រណារីវង្ស (សុជារស) ។ សម្ដេចក៏ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានបង្រៀនប្រដៅនូវកិច្ចគារវៈផ្សេង ៗ ជាច្រើន ។ ទ្រង់ព្រះរាជទានក្បួនរាជសព្ទ អក្ខរវិធីតាំងរបៀបសរសេរនិងនិយាយឲ្យត្រឹមត្រូវតាមទំរង់សក្តិ ។

ដល់មក គ.ស.១៩៤៥ ព្រះបាទសម្ដេចព្រះ ន. សីហនុ វរ្ម័ន ព្រះចៅព្រះរាជាណាចក្រកម្ពុជាធិបតី ជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសព្រះរាជទានខ្ញុំឲ្យធ្វើជាឧកញ៉ាមហាមន្ត្រី តាងហ្លួងព្រះរាជមន្ទីរក្នុងព្រះបរមរាជវាំង ។ ខ្ញុំបានចូលគាល់បំរើក្រោមព្រះបាទយុគលរៀងមក តែពុំបានឃើញមានច្បាប់ក្បួន របៀបខាងមន្ត្រីនិងប្រជារាស្ត្រឡើងក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ជាម្ចាស់ផែនដីនិងខត្តិយត្រកូលផ្សេង ៗ ទុកជាក្បួនមកសោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនេះហើយខ្ញុំតាំងព្យាយាមសរសេរក្បួននេះឡើង ហើយបានបោះពុម្ពជាសៀវភៅទុកគ្រាន់ចែកជនានុជន ដែលពុំបានដឹងសព្វគ្រប់ក្នុងការកិច្ច ។ មួយទៀត ក្រៅអំពីទម្លាប់ទំនៀមស្រុករបស់យើង ខ្ញុំបានយករបៀបអឺរ៉ុបខ្លះដែលយើងនិយមប្រើដែរ មកបញ្ចូលផង ។

ខ្ញុំនឹងសរសេរតទៅទៀតក្នុងសៀវភៅភាគទី ២ ។

ឧកញ៉ាមហាមន្ត្រី

ញ៉ុក - ធ្យូ

# គារវកិច្ច

គារវកិច្ច ជាវិន័យមួយធំបំផុតសំរាប់មនុស្សទាំងសកលលោកទាំងមូល គ្រប់ជាតិគ្រប់សាសន៍ត្រូវរៀនឲ្យចេះដឹងមិនឲ្យខ្វះខាតត្រង់ណាមួយឡើយ តាមទម្លាប់ទំនៀមប្រទេសរៀង ៗ ខ្លួននិងទម្លាប់ទំនៀមបរទេសខ្លះទៀតផង សំរាប់ប្រើប្រាស់តាមកាលៈទេសៈ ព្រោះមានកាលខ្លះគារវកិច្ចនេះត្រូវប្រតិបត្តិតាមរបៀបស្រុកទេសយើង មានកាលត្រូវធ្វើតាមរបៀបស្រុកទេសគេដែលយើងចូលទៅ ។

ឧបមាដូចអ្នកស្រុកក្នុងអាស៊ីទ្វីប នោះច្រើនអង្គុយរាបគឺអង្គុយលើកន្ទេល លើក្តារឬអង្គុយលើគ្រែផ្សេង ៗ មានក្តារនៀជាដើម តែរបៀបអង្គុយខុស ៗ គ្នា ៗ ខ្មែរ - សៀម - លាវអង្គុយបត់ជើង ចិន - យួនអង្គុយពែនភ្នែន... តាមបុរាណកាល ។ ដល់មកសម័យអារ្យធម៌អឺរ៉ុបចូលមក របៀបនៃគារវកិច្ចបុរាណក៏ប្រែក្លាយខ្លះ បន្តិច ៗ ម្តងរៀងមក តែពុំទាន់បាត់លុបទាំងអស់ទេ គ្រាន់តែកាត់ខ្មែរខ្លះ - សៀមខ្លះ - យួនខ្លះ លាវខ្លះ - និងអឺរ៉ុបខ្លះ តាមអ្នកស្រុករាប់អាន ។

ដូច្នេះគារវកិច្ចកើតនៅក្នុងឥរិយាបថទាំង ៤ ជាដើម ថែមវាចានិងកិរិយាផ្សេង ៗ ខ្លះមកទៀត ដូចជាថ្វាយបង្គំ, សំពះ, ក្អក, កណ្ដាស, ហាក; ស្តោះ; សើច ។ល។

www.budinst.gov.kh www.elibraryofcambodia.org

មិនមានតែទម្លាប់ទំនៀមរបស់បច្ចុប្បន្នលោកនេះទេ ធម្មចរិយាមាន តាំងពីពុទ្ធកាលមកគឺពុទ្ធភាសិតក៏មាន បុរាណភាសិតក៏មាន ។

ពុទ្ធភាសិតគឺ សប្បុរិសធម៌ ៧ យ៉ាង ៖

១.– ធម្មញ្ញុតា ភាពជាអ្នកស្គាល់ហេតុនៃសេចក្តីសុខនិងទុក្ខ ។

២.– អត្ថញ្ញុតា ភាពជាអ្នកស្គាល់ផលគឺសុខនិងទុក្ខកើតអំពីហេតុ ។

៣. អត្តញ្ញុតា ភាពជាអ្នកស្គាល់ខ្លួនថា “ អាត្មាអញនេះមាន ជាតិត្រកូល, យស, សក្តិ, សម្បត្តិ, បរិវារ, សេចក្តីចេះដឹងនិង គុណធម៌ក្នុងខ្លួនត្រឹមណា. ហើយប្រព្រឹត្តតាមគួរដល់ឋានៈរបស់ខ្លួន” ។

៤.– មត្តញ្ញុតា ភាពជាអ្នកស្គាល់ប្រមាណក្នុងការរកចិញ្ចឹម ជីវិតដោយប្រពៃនិងការបរិភោគ ។

៥.– កាលញ្ញុតា ភាពជាអ្នកស្គាល់វេលាដែលគួរនឹងប្រកបកិច្ច ការនោះ ៗ ។

៦.– បរិសញ្ញុតា ភាពជាអ្នកស្គាល់ប្រជុំជន គឺត្រូវធ្វើកិរិយាយ៉ាង នេះៗ ត្រូវនិយាយយ៉ាងនេះៗ ឲ្យសមតាមលក្ខណៈប្រជុំនោះ ។

៧.– បុគ្គលបរោបរញ្ញុតា ភាពជាអ្នកស្គាល់បុគ្គល ថាអ្នកនេះ ល្អ អ្នកនេះ អាក្រក់ គួរគប់រក ឬ មិនគួរគប់រក ។

*

www.budinst.gov.kh www.elibraryofcambodia.org

# បុរាណភាសិត

ចាស់ៗលោកច្រើនប្រដៅកូនចៅ ដោយភាសិតផ្សេងៗ ដើម្បីដឹកនាំកូនចៅ, ឲ្យស្គាល់ធម្មចរិយា ឲ្យស្គាល់សម្បត្តិមនុស្សល្អ ឲ្យចេះរក្សាពូជពង្សវង្សត្រកូលឲ្យសមគួរតាមឋានៈនិស្ស័យបុណ្យសក្តិគ្រប់ៗគ្នា ។

ដូចជា ៖

១.– ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់ ។

២.– ស៊ីឲ្យសាប អង្គុយឲ្យទាប ស្តីឲ្យសុភាព បុកឲ្យខ្ទស់

៣ – ប្រពន្ធល្អ ច្រើនចាញ់ប្តី ... ។ល។

៤.– ពាក្យច្រើនកូតចាញ់អាត្មា ... ។ល។

៥.– សំដីសរជាតិ មារយាទសរត្រកូល ... ។ល។

៦.– សិរសាទន់ទាប សុភាពចុះអង្គ ... ។ល។

នឹងអធិប្បាយក្នុងឥរិយាបថទាំង ៤ ជាដើមគឺ ដេក, អង្គុយ, ឈរ, ដើរ ។

## ដំណេក

បុរាណភាសិតប្រដៅថា "ដំណេកដេកជាខ្នាត ឲ្យសំអាតសំអាន ជា ទើបទេព្តារក្សា ចំរើនសុខស្រីសួស្តី" ។

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យលោកទូន្មានយើងកល់គ្នាឲ្យរៀបចំដំណេកឲ្យមានខ្នាតគឺឲ្យមានទីកន្លែងដេកបិទបាំងឲ្យជាប់មុប់ ដាច់ដោយឡែកអំពីកន្លែងទទួលភ្ញៀវនិងកន្លែងអាស្រ័យបាយទឹក ។ បើរៀបផ្ទះសម្បែងឲ្យច្រឡំកន្លែងដំណេកនឹងកន្លែងទទួលភ្ញៀវឬកន្លែងអាស្រ័យបាយ នោះមិនរាប់ថាជាខ្នាតទេ ។

“ ឲ្យសំអាតសំអាងជា ” គឺឲ្យបោសច្រាសត្រក់សទីដំណេកឲ្យស្អាត នោះតើយ៉ាងណាវិញ? ត្រង់នេះ ក៏សមប្រកបគ្នានឹងតម្រាអនាម័យ ក្នុងសកលលោកទាំងមូល ។ ធម្មតាអ្នកស្អាតតែក្រោកឡើងពីដំណេកហើយរមែងពាក់មុងឬរុំមុងឲ្យបានរៀបរយល្អ រួចទើបលាស់ភួយ, ផាហ៊ុំ បោសត្រក់សពូក រៀបចំកំរាលពូក ខ្នើយកើយ, ខ្នើយឱប, ខ្នើយជើង ឲ្យបានត្រឹមត្រង់ល្អឡើងវិញដូចកាលមុនពេលដេក យ៉ាងនេះតែរាល់ថ្ងៃឥតមានខាន ។ ម្ល៉ោះហើយលោកពោលថា “ទើបទេវតារក្សា ចំរើនសុខស្រីសួស្តី” ថាទេវតានឹងរក្សាថែទាំអ្នកដែលស្អាតនោះ ទាំងជួយចំរើនទូវសេចក្តីសុខដល់អ្នកនោះទៀត នេះបើយើងគិតតាមការគិតខាងលើនេះ ។ តែបើពិគ្រោះតាមតម្រាអនាម័យវិញ ក៏បានសេចក្តីដូចគ្នា ។ ព្រោះថាបើយើងព្យាយាមសំអាតដំណេកមិនឲ្យធូលី, សម្រាម, ក្រឡាកឬវត្ថុស្មោកគ្រោកមាននៅលើដំណេកយើង មេរោគក៏ពុំអាចបង្កើតជាជម្ងឺអ្វីមួយដល់រូបកាយយើងបានឡើយ

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះហើយសុខគង់មានដល់យើងច្រើនជាងទុក្ខគឺថា ពុំសូវមានរោគាពាធបៀតបៀនករដ្ឋកាយឲ្យទន់ទាបទុព្វលភាពដុនដាបទៅឆាប់ពេក ។

*

* *

## ឥរិយាបថ ទី១

### — ដេក —

កិរិយាដែលដេកនោះមានលក្ខណៈប្រពៃណាស់ តាមកាល តាមដំណើរ, តាមទំនង ។ តាមធម្មតាបើយើងចូលដំណេកត្រូវរៀបកន្ទេល ពូកខ្នើយ បោសសំអាតទីដំណេកឲ្យស្អាតហើយបិទទ្វារបន្ទប់ឲ្យគត់មត់ ។

អ្នកទាំងឡាយមានផ្ទះយ៉ាងណា គឺមិនត្រូវបោនបើកទ្វារបន្ទប់ដំណេកគេឯងទៀយ ។ បើមានកិច្ចជាអាសន្ន គប្បីស្រែកហៅ ឬគោះទ្វារដ៏ញ៉ាំងហៅឲ្យចេញមកនិយាយផង ។ កុំគប្បីចូលទៅក្នុងបន្ទប់ដំណេកគេឲ្យសោះ បើគេពុំបានអញ្ជើញឲ្យទៅទេ ។

អ្នកដែលមានដំណេកល្អ ចេះប្រយ័ត្នខ្លួនដោយមិនបោះជើងបោះដៃច្រវេងច្រវាង ចេះប្រយ័ត្នសំពត់អាវ ចេះរៀបខ្លួនឲ្យស្រួលបួលមុននឹងលក់ស្កប់ទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

# ក្មេងត្រូវគោរពចាស់

មាតា, បិតា, គ្រូអាចារ្យចាស់ទុំ ដែលជាអ្នកថែរក្សាព្យាបាលក្មេង ត្រូវបង្ហឹកបង្ហាញឲ្យចេះគោរពកិច្ចនេះ តាំងពីនៅតូច ដល់ធំឡើង កូនចៅរបស់យើងនឹងចេះដើរយកតម្រាប់តាម ។

មួយទៀត បើម្ដាយ-ឪពុក កំពុងអង្គុយលេង មិនត្រូវឲ្យកូនចៅដេកសំយុងជើងមកលើឡើយ ។

អ្នកដេកហើយតែពុំទាន់លក់ បើមានព្រះសង្ឃ, ក្សត្រ, មន្ត្រី, ចាស់ព្រឹទ្ធាចារ្យ ដើរមកជិតនោះត្រូវក្រោកអង្គុយឬអង្គុញជើងគួរសម ទើបជាចរិយាល្អមួយ ។ បើចាស់អាស្រ័យដំណេកនៅកន្លែង ១ ក្មេងមិនត្រូវទៅដេកទន្ទឹមឬដេកសំយុងជើងលើចាស់នោះឲ្យសោះឡើយ ឬទៅធ្វើអ្វីជាការមិនគប្បីជាដំណើរឲ្យរំខានដល់អ្នកអាស្រ័យដំណេកនោះ ទាល់តែខានលក់ទៅ ។

គេអង្គុយកល់គ្នាក្នុងទីប្រជុំ យើងមិនត្រូវទៅដេកជិតដែនអ្នកអង្គុយប្រជុំនោះឡើយ យើងមិនត្រូវយកកូនចៅទៅឲ្យដេកនៅទីនោះទៀត ។ បើកូនចៅងងុយដេកត្រូវតែនាំយកទៅផ្ទះ (ត្រង់នេះបានអ្នកស្ដាប់ទេសន៍ជាដើមយកកូនចៅទៅឲ្យដេកជិតខ្នងរំខានគេឯងកល់គ្នា) ។

អ្នកដែលជាពុទ្ធមាមកៈ ពុទ្ធមាមកា តែងតែមានកន្លែងរៀបកោះបទះធ្វើសក្ការបូជាមានព្រះបដិមាករជាដើម នៅក្នុងផ្ទះសម្បែងក្នុងកន្លែងណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

ដោយគួរសម ។ ដូច្នេះក្នុងកិច្ចគោរពមិនត្រូវអាស្រ័យដំណេកដេកសណ្ដូកជើងត្រង់ទៅទីនោះឡើយ សូម្បីតែកូនចៅដែលមិនទាន់ដឹងក្ដី ក៏គប្បីទូន្មានឲ្យវាច្បាប់ឲ្យចេះគោរពក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើម ។

បើដឹងពេលឲ្យក្រិដ្ឋទៅទៀតជាទៅក្នុងផ្ទះទីមួយៗគប្បីកុំឲ្យកូនចៅដែលបានបន្ទប់ដំណេកផ្សេងពីមាតាបិតាទៅ ហើយដេកយកជើងទៅរកបន្ទប់ដំណេកមាតាបិតាឡើយ ។

មូលសេចក្ដីទៅ ត្រូវចាំថា យើងត្រូវគោរពបុគ្គលទាំងឡាយដែលគួរគោរព ទីកន្លែងទាំងឡាយដែលគួរគោរព យើងមិនត្រូវដេកសណ្ដូកជើងទៅត្រង់បុគ្គលនោះៗ ទៅត្រង់ទីនោះៗជាដាច់ខាត ។

(ត្រង់អធិប្បាយចេញថា "ក្មេង" ថា "ចាស់" នោះត្រូវលើកយកអ្នកមានបណ្ដាសក្ដិធំនិងបក្ដិភូចនិងស្ត្រីសាមញ្ញ មកប្រៀបផ្ទឹមផងជាគោលចារឹក ក្នុងកិច្ចគោរពនិងសេចក្ដីគួរសមកាន់គ្នានឹងគ្នា ) ។

※

※ ※

## ឥរិយាបថទី ២

## អង្គុយ

អង្គុយមានច្រើនជាន់ច្រើនថ្នាក់ ៗ បើរៀបតាមបែបយ៉ាងនោះមានតែពីរយ៉ាង គឺអង្គុយកបង់អង្គុយកៅអី ៗ បែបទាំងពីរយ៉ាងនេះត្រូវចាត់តាមជាន់តាមថ្នាក់ជាដើម មិនត្រូវឲ្យក្លាត់បានហើយឲ្យសមតាម

www.budinst.gov.kh www.elibraryofcambodia.org

ពេលតាមពិធីនោះៗផង ។ អ្នករៀបកន្ទេលជាបច្ច័យនឹងអ្នកអង្គុយ ។ ហេតុដូចម្តេច ?

ថាអ្នករៀបកន្ទេលត្រូវចេះរៀប ឯអ្នកអង្គុយត្រូវស្តាប់អ្នកជូនកន្ទេល គឺថាភ្ញៀវត្រូវទទួលកន្ទេលដែលគេអញ្ជើញឲ្យអង្គុយ បើភ្ញៀវចេះតែដដែក ប្រកែកមិនព្រមទទួលតាមគេអញ្ជើញឲ្យអង្គុយ នោះរបៀបដែលអ្នកចាត់ការប្រឹងប្រៀបទុករបៀបតែនឹងខូចអស់ ម្ល៉ោះហើយពិធីដែលធ្វើនេះក៏ពុំបានរៀបរយល្អ ។

មួយសោតឯអ្នករៀបកន្ទេលរៀបភ្ញៀវទៀត ត្រូវឲ្យដឹងឋានៈនៃភ្ញៀវ តែលើកគេពេកប្អាក់គេពេក គេកើតទោមនស្ស គេពុំអាចទទួលកន្ទេលនោះបាន ។

*

*  *

## ទីអង្គុយជាធុរការ
## (ព្រះសង្ឃ)

ក្នុងពិធីនីមួយៗ ដែលជាព្រះរាជពិធីក្តី ជាពិធីនៃរដ្ឋាភិបាលក្តី មិនថាពិធីធំឬតូចឡើយ នោះបណ្តាព្រះសង្ឃដែលមានសមណសក្តិជាទីរាជាគណៈ ទីឋានានុក្រម នាម៉ឺនសព្វមុខមន្ត្រីធំ-តូច ត្រូវមានទីអង្គុយតាមយសសក្តិ ។

ចំណែកសមណសក្តិ ព្រះសង្ឃត្រូវគង់តាមលំដាប់សក្តិដែលព្រះមហាក្សត្រតាំងប្រគេន នោះតាមរបៀបគឺព្រះសង្ឃនាយកមក ត្រូវព្រះរាជាគណៈ ទី ១ ទី ២ ទី ៣ ទី ៤ ព្រះគ្រូ-បាឡាត់-សមុហ៍-វិបដីកា ។ល។

សមណសក្តិនេះ មានឋានៈសំគាល់ឋានៈ ។ ចុះបើព្រះរាជាគណៈ ទី ១ ទីង ទី ១ ទី ២ ទីង ទី ២... ។ល។ មកជួបគ្នានោះត្រូវគង់តាមចំនួនវស្សាចាស់ខ្ចី នៃយសសក្តិ មិនមែនកាប់យកតាមចំនួនវស្សាផ្សេងទេ ឬចំនួនឆ្នាំជន្មាយុទេ ។

បើជាក្រៅពីផ្លូវការវិញ ទៅទីប្រជុំកុសលកម្មឬតាមគេហស្ថាន ឧបាសក-ឧបាសិកានោះយើងគប្បីចូលចិត្តឲ្យបានថា គណសង្ឃដែលយើងនិមន្តលោកមកនោះ លោកគង់តាមលំដាប់វស្សាចាស់-ខ្ចី មិនមែនគិតតាមព្រះជន្មលោកទេ គឺតាមបញ្ញត្តិគង់វិន័យដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រញ្ញត្តិទុកមក ។

មិនតែប៉ុណ្ណោះទេ ត្រូវយើងរៀបសេនាសនៈថ្វាយព្រះសង្ឃឲ្យខ្ពស់ជាងគ្រហស្ថផង គឺថាយ៉ាងទាបណាស់ត្រឹមកន្ទេលពីរជាន់ ឬកន្ទេល ១ ជាន់ ព្រំពៀម ១ ជាន់ ។ យើងជាគ្រហស្ថត្រឹមកន្ទេល ១ ជាន់បានហើយ ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## គ្រហស្ថ — ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ

នៅក្នុងព្រះបរមរាជវាំង កាលមានព្រះរាជពិធីធំៗ មានសម្ពោធ ៗ ដែលព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងស្តេច យាងចេញជាព្រះរាជាធិបតី នោះបណ្ដាភ្នាក់ងារ ត្រូវរៀបចំព្រះទីនាំងថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាខាងដើម - ខាងមុខបង្អស់ បន្ទាប់មកថ្វាយព្រះរាជវង្សានុវង្សក្សត្រាជាទី ២, គណៈរដ្ឋមន្ត្រីទី ៣ មន្ត្រីសក្តិ ១០ ហ៊ូពាន់ទី ៤, ( ឧត្តមមន្ត្រីផុតលេខ, តាងហ្វាងសាលាវិនិច្ឆ័យ ) គឺទៅ វរមន្ត្រី, អនុមន្ត្រី, ក្រមការ... ៗល ៗ យ៉ាងនេះ ជារបៀប ជាទម្លាប់-ទំនៀម ៗ

ព្រះរាជវង្សានុវង្សក្សត្រាដែលឡើងគាល់ត្រូវគង់ជាមួយគ្នាទាំងអស់នៅកន្លែងមួយ ដែលមុខងារបានចាត់ទុកថ្វាយ ៗ ការគង់នេះ ត្រូវប្រាប់ព្រះអង្គគង់តាមថ្នាក់សក្តិយសធំ-តូចជាលំដាប់ ៗ

ចំណែកខ្ញុំរាជការដែលគាល់បំរើផ្ទាល់ព្រះអង្គព្រះករុណា ជាអម្ចាស់-ជីវិតលើត្បូង នោះត្រូវមានកន្លែងអង្គុយគាល់ដោយឡែក ដែលក្រុមព្រះរាជមន្ទីររៀបចំបំរុងទុកជារបៀបស្រេចៗ ៗ ដូច្នេះព្រះរាជវង្សានុវង្សក្តី អស់លោកមន្ត្រីធំ-តូចក្តី ត្រូវទទួលយកទីបង្គុយដែលតាងហ្វាងព្រះរាជមន្ទីរ បានអញ្ជើញស្តេចគង់ - អញ្ជើញអង្គុយ ទើបមានរបបរបៀបរៀបរយល្អ តាមច្បាប់តាមទំនៀម ៗ

ខាងស្ត្រីវិញក៏មានរបៀបប្រហែលៗគ្នាជាទម្លាប់ទំនៀម ៗ

www.budinst.gov.kh www.elibraryofcambodia.org

នាក្រោយព្រះមហាស្វេតច្ឆត្រជាកន្លែងសម្រាប់ស្ដេចគាល់ព្រះមហាក្សត្រាធិបតីគ្រប់ព្រះរាជពិធីទាំងសមាស ។ នោះនៅពីក្រោយព្រះមហាស្វេតច្ឆត្រ ត្រូវចាត់ជា ៣ រយៈ ទី ១ សម្រាប់ថ្វាយសម្ដេចព្រះជននីនាថ, សម្ដេចព្រះមាតុច្ឆា, សម្ដេចព្រះបិតុច្ឆា ។ល។ ទី ២ បន្ទាប់តទៅខាងក្រោយ ក្សត្រិយ៍ព្រះអង្គម្ចាស់និងអ្នកអង្គម្ចាស់ – ទី ៣ ខាងក្រោយបង្អស់ ចៅផិត, ចៅចម (អស់អ្នក) ។

នាខាងស្ដាំទីតាំង ៣ នេះ គង់ល្វែងដោយខ្ទង់សំរាប់ចំពាវខុនណាង (គឺការិយាមន្ត្រីធំ-តូច) នោះក៏មានរបៀបតាមឋានន្តរសក្តិនៃស្វាមីទាំងអស់ ។

ដែលលើកយករបៀបទីតាំងក្សត្រហាងព្រះករុណាជាម្ចាស់ជីវិតលើត្បូងជាប្រធានដោយចុះមកព្រះរាជវង្សានុវង្សជាលំដាប់ទាំងក្សត្រិយ៍ក្សត្រា ទាំងនាម៉ឺនសព្វមុខមន្ត្រីកវីបណ្ឌិត ចៅផិតចៅចម បំពាវខុនណាង មកជាគំរូយ៉ាង ដើម្បីជាបែបផែនពន្យល់បំភ្លឺរបៀបរៀបចំសេនាសនៈ ទទួលភ្ញៀវឲ្យបានសមរម្យកុំឲ្យខុសឆ្គងពេក ។

បើយើងយល់របៀបនេះបានហើយ កាលគ្រាយើងមានកិច្ចធុរៈបុណ្យទានឬរៀបពិធីមង្គលការផ្សេងៗ មានអញ្ជើញស្ដេចក្សត្រិយ៍ខត្តិយវង្ស នាម៉ឺនធំ-តូច ព្រៀងការ ញាតិសាច់សាលោហិត មិត្តភក្តិមកជាអធិកអធម នោះគប្បីចាត់ទីកន្លែងឲ្យសមតាមយសសក្តិជាដរាប ។



www.budinst.gov.kh www.elibraryofcambodia.org

នេះចំណែកខាងក្សត្រិយ៍ និងមន្ត្រី ក៏ល្មមចូលចិត្តបាន ។

ចំណែករាស្ត្រសាមញ្ញគឺអ្នកផងបណ្ដាសក្តិនោះ គេត្រូវកប់យកចាស់ព្រឹទ្ធាចារ្យជាធំក្នុងទីប្រជុំនីមួយៗ ។ ប្រៀបដូចយើងធ្វើបុណ្យនិមន្តព្រះសង្ឃចំរើនព្រះបរិត្តនៅផ្ទះយើងឬនៅវត្តនោះគេដាក់លោកអាចារ្យ (គឺអ្នកនាំថ្វាយបង្គំព្រះ សូមសីល . . . ។ ល ។) ឲ្យអង្គុយមុខបង្អស់នៅកណ្ដាលទីប្រជុំ បន្ទាប់គ្នាៗមកក្រោយ គេអញ្ជើញលោកចាស់ៗ ឡើងទៅជិតលោកអាចារ្យ ទើបក្មេងៗជាលំដាប់ចុះមក ។ តែបើមាននាម៉ឺនធំ តូច អញ្ជើញមកខ្លះផង គប្បីអញ្ជើញអស់លោកទាំងនោះអង្គុយជិតស្មើផ្លូវនឹងលោកអាចារ្យទើបសម ។ ស្ត្រីនិងបុរសក៏ត្រូវញែកជាពួកនៅក្នុងទីនោះ គឺតាមប្រវេណីខ្មែរពីបុរាណមក ការប្រជុំធ្វើបុណ្យឬធ្វើពិធីអ្វីនីមួយៗ គេតែងតែផ្គុំស្រីដោយស្រី ប្រុសដោយប្រុស ថ្វីបើប្ដីប្រពន្ធមកពីផ្ទះជាមួយគ្នា តែដល់ទៅទីប្រជុំគេតែងតែបែកគ្នាទៅរកទីកន្លែងតាមស្រីតាមប្រុសជាធម្មតា ។ នៅគេហស្ថានរបៀបរៀបក្បៀវនេះស្រេចហើយនៅលើម្ចាស់បុណ្យឬអ្នកចាត់ការ ។ នៅទីវត្តវិញស្រេចហើយតែលោកអាចារ្យ ជាប្រមុខចាត់ចែងធ្វើកាលទានឬបុណ្យទ្វាទសមាសដែលលោកអាចារ្យមានស្នាកឬកម្មវិធី ចែកចាយផ្សាយដំណឹងអញ្ជើញទាយកទាយិកាជើងវត្តមក ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## តាមអារ្យធម៌អឺរ៉ុប

បណ្ដាអារ្យជននៅប្រទេសអឺរ៉ុបដែលទៅកាន់ទីប្រជុំនីមួយ ៗ តាមសេចក្ដីអញ្ជើញរបស់សមាគមណាមួយ ឬរបស់ឥស្សរជនណាមួយ ដូចជាទៅស្ដាប់សន្និសីទ ឬបាឋកថា ... ។ល។ នោះគេពុំមានអង្គុយទន្ទឹមគ្នាប្ដីប្រពន្ធ ៗ ។

ទាំងទៅមើលល្បែងល្ខោនកំប្លែងនឹងល្បែងផ្សេង ៗ ... លោកអ្នកដែលអញ្ជើញទៅ ក៏តែងតែអង្គុយជាគូ ៗ ភរិយាស្វាមីជាដរាប ជួនកាលមានទាំងកូនស្រីប្រុសទៅជាមួយផង នោះគេអាចអង្គុយតាមជួរតាមក្រុមគ្រួសារទៅបានជាទម្លាប់ ។

## តាមឱវាទពីបុរាណកាល

ចាស់ ៗ ច្រើនទូន្មានកូនចៅថា «ត្រូវអង្គុយឲ្យទាប» តើយ៉ាងណាមិញ ? ។ ក្នុងពេលប្រជុំម្ដង ៗ រមែងមានជនគ្រប់ជាន់គ្រប់ថ្នាក់ ក្សត្រិយ៍, មន្ត្រី, រាស្ត្រសាមញ្ញស្រីប្រុស ចាស់ក្មេងជាធម្មតា, ហើយលោកឲ្យទូន្មានយើងទាំងអស់គ្នា ឲ្យអង្គុយឲ្យទាប ៗ ចុះទីត្រង់ណាដែលយើងសំគាល់ទុកថាជាទីទាប ? ។

យើងរាល់គ្នាត្រូវឲ្យដឹងឋានៈ របស់យើង យើងអាចស្គាល់បាន ចូលចិត្តបានថាក្នុងប្រជុំនេះ (មិននិយាយពីប្រជុំជាផ្លូវការទេ) គឺអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ស្រុកភូមិផងល្បងជាមួយ ញាតិសាច់ទឹងមិត្តភក្តិ... ។ល។, ដូច្នេះ យើងអង្គុយត្រង់នេះ ជាទីគួរសម តែយើងកុំគប្បីទៅអង្គុយដល់ទីនោះភ្លាមទេ យើងគប្បីរើសយកទីបន្ទាប់អំពីនោះបន្តិចមក យ៉ាងនេះហើយហៅថាអង្គុយឲ្យទាប ព្រោះយើងប្រាកដក្រែងមានលោកអ្នកធំជាងយើង ឬចាស់ជាងយើង. អញ្ជើញមកទៀតមិនរលំទឹងរើកខ្ទង ។

មួយវិញទៀត ក្នុងពេលប្រជុំនោះ បើមានមន្ត្រីចាស់ (រ៉ឺត្រែត) ដែលលោកមានយសសក្តិធំខ្ពស់ដែរ ឬមានចាស់ព្រឹទ្ធាចារ្យដែលប្រកបដោយលក្ខណៈ ជាអ្នកស្រគត់ស្រគំ អ្នកសមាទានរក្សាសីលសមរម្យជាទីគោរពរបស់យើង ទុកដូចជាឪពុកយើង - ម្តាយយើង - ជីដូន - ជីតាយើង យើងគប្បីអញ្ជើញឲ្យចិតឡើងទៅមុខបន្តិចក៏គួរដែរ ទុកណាជាយើងជាមន្ត្រីធំក្តី តូចក្តី ដែលនៅឆាពេញទី ។ ចំណែកខាងស្រីៗ គឺគប្បីប្រើរបៀបអង្គុយដូចអធិប្បាយហើយខាងលើនេះ ។

របៀបអង្គុយនឹងឲ្យរៀបរយបានល្អអាស្រ័យភ្ញៀវនឹងការគួរសមឲ្យបរិបូណ៌ផង បើភ្ញៀវឥតល្បប់មិនគិតក្រែងមានការរំខានដល់ភ្ញៀវនឹងភ្ញៀវផងគ្នា ឬដល់អ្នកម្ចាស់ផ្ទះ ម្ចាស់បុណ្យ នោះជាអំពើឲ្យកើតឡើងនូវសេចក្តីមិនស្រួលក្នុងទីប្រជុំឬបង្កើតនូវសេចក្តីចង្អៀតបង្អល់ចិត្តគេឯងពលគ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

# (ក្មេង)

ក្នុងទីប្រជុំទីមួយ ៗ ត្រូវប្រយ័ត្នកូនក្មេងដែលឥតល្បកុំឲ្យចូលទៅដណ្ដើមកន្លែងចាស់ៗអង្គុយ ។ មានក្មេងខ្លះអង្គុយហើយមិននៅស្ងៀមទៀតផង ចេះតែក្រោកដើរចេញចូលកណ្ដាលផ្លូវដើរចាស់ទុំឥតកោតញញើត ។ ក្មេងខ្លះមិនព្រមអង្គុយកបទីកន្លែងទេ ចារអង្គុយលើភ្លៅម្ដាយឬជីដូន ខ្លះក៏បានអង្គុយលើភ្លៅម្ដាយហើយ មានការចាប់ចាបកេចសំពត់អាវម្ដាយ ឬចារយកនេះយកនោះទៀត ។

ចំណែកខាងអ្នកអង្គុយកៅអីក៏ដូចគ្នា មានលោកអ្នកខ្លះយកកូនចៅទៅផង ហើយយកទៅឲ្យអង្គុយកៅអី ១ ។ បើយ៉ាងនេះភ្ញៀវម្នាក់មានក្មេងម្នាក់ទៅផង នោះអ្នកផ្ទះរកកៅអីនិងទីកន្លែងជូនភ្ញៀវពុំគ្រប់គ្រាន់ទេ ។ មានកាលមិនមែនកូនចៅរបស់ភ្ញៀវទេ គឺកូនចៅរបស់អ្នកផ្ទះ បណ្ដោយឲ្យមកដណ្ដើមកន្លែងភ្ញៀវ ៗ ពុំដឹងធ្វើដូចម្ដេចក៏ស្ងៀមតែឈរទៅ ចំណែកភ្ញៀវអង្គុយកបក៏ត្រូវតែស៊ូទ្រាំចង្អៀតទៅ ។

ហេតុដែលនាំឲ្យខូចរបៀបអង្គុយយ៉ាងនេះ យើងអាចនឹងកែរួចស្រួលឡើងវិញបាន គឺថាយើងជាភ្ញៀវមិនត្រូវយកកូនចៅទៅផងទេ ព្រោះគេអញ្ជើញតែត្រឹមយើង គេពុំបានអញ្ជើញកូនចៅយើងទេ ។ ចំណែកអ្នកផ្ទះត្រូវដឹងខ្លួនឲ្យច្បាស់ថា អញពុំបានអញ្ជើញកូនចៅគេទេ ដូច្នេះ ត្រូវកុំបណ្ដោយកូនចៅអញឲ្យទៅរំខានភ្ញៀវ ។

www.budinst.gov.kh www.elibraryofcambodia.org

ចុះបើទៅប្រជុំនៅនាវត្តអារាម នោះទម្លាប់ខ្មែរគេតែងតែយកកូនចៅទៅផង ដើម្បីឲ្យកូនចៅចេះចង់ធ្វើបុណ្យតាមទម្លាប់ឲ្យស្គាល់ឲ្យស្រឡាញ់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលជាទីពឹងរបស់ខ្លួន ជាពុទ្ធមាមកជន ។ ការដែលយកកូនចៅទៅវត្តជាកិច្ចប្រសើរក្រៃពេក តែបើនាំយកទៅហើយបណ្តោយឲ្យឥតល្បប ក៏ត្រឡប់ជាមិនប្រសើរវិញ ។

ពេលប្រជុំយ៉ាងសំខាន់ ដែលមិនត្រូវយកកូនចៅទៅជាមួយផងឲ្យសោះ ។ ត្រង់នេះយើងរាល់គ្នាគប្បីចូលចិត្តបានថា ប្រជុំណាមួយដែលគេតែងរាប់ចំនួនភ្ញៀវឲ្យមានកំណត់ថា មានប៉ុណ្ណេះប៉ុណ្ណោះ ។ ភ្ញៀវត្រូវប្រតិបត្តិតាមសំបុត្រអញ្ជើញ នោះយ៉ាងណាមិញ ? ជាបើគេអញ្ជើញតែស្វាមី នោះភរិយាពុំគប្បីទៅផងទេ ។ បើគេអញ្ជើញទាំងស្វាមីភរិយា នោះកុំគប្បីយកកូនចៅទៅផងឡើយ ។ បើគេអញ្ជើញគ្រួសារទាំងមូល ទើបទៅទាំងអស់គ្នាបាន ។ ចុះដោយហេតុដូចម្តេច ?

នឹងលើកឧទាហរណ៍១ជាតួយ៉ាងមកអធិប្បាយពន្យល់ជូនឲ្យឃើញការទាស់ ។

ប្រៀបដូចក្នុងពិធីរៀបអាពាហ៍ពិពាហ៍ គេតែងលៀងភ្ញៀវជាកិត្តិយសដោយមេត្រីរាប់អានវង់មិត្តភក្តិនឹងសាច់សន្តាន ។ អ្នកដើមការតែងតែគិតចំនួនភ្ញៀវ ចំនួនកៅអី ចំនួនតុ ឲ្យត្រូវគ្នាកុំឲ្យមានខ្វះខាតខ្មាសក្រែងភ្ញៀវអន់ចិត្ត ។ បើប្រសិនជាសល់តុវិញនោះពុំជាការអ្វីឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ត្រង់នេះហើយជាហេតុបណ្ដាលឲ្យយើងជាភ្ញៀវ កុំគប្បីយកកូនចៅទៅផង ដែលអ្នកដើមការពុំបានគិតទីកន្លែងនិងម្ហូបចំណីទុកឲ្យ ។ មិនតែប៉ុណ្ណោះទេ ត្រូវដឹងថា គេតែងកំណត់ទុក រៀបទុកជាមុនឲ្យឃើញថា ក្នុង ១ តុ ត្រូវដាក់ភ្ញៀវ ៦ នាក់ឬ ៨ នាក់ ... ។ ចុះបើភ្ញៀវណាមួយមានកូនម្នាក់យកទៅផង ហើយនិយាយសុំកៅអី ១ ទៀត ចានបាយ ១ ទៀត សមស្លាបព្រា ១ សំរាប់ទៀត តើឲ្យគេទៅរកឯណាមកឲ្យយើង? នេះហើយជាហេតុដែលយើងធ្វើឲ្យគេរំខាន ឲ្យខូចរបៀបរៀបរយរបស់គេ ។ យើងគប្បីគោរពរបៀបគេឲ្យបានបរិបូណ៌ ។

ដូចប្រជុំមើលល្បែងរបាំផ្សេង ៗ ក្តី ប្រជុំស្តាប់សន្និសីទក្តី ... ។ល។ ដែលជាប្រជុំមានកំណត់ទីបង្គុយតាមចំនួនភ្ញៀវ នោះភ្ញៀវមិនត្រូវដឹកនាំយកអ្នកដទៃទៅផងទេ ឲ្យលើសពីសំបុត្រអញ្ជើញរបស់គេ ។

## លក្ខណៈអង្គុយនៅមុខអ្នកធំ

ពាក្យថាអ្នកធំមួយម៉ាត់នេះ សំដៅយកព្រះសង្ឃ, ក្សត្រិយ៍, មន្ត្រី, ចៅហ្វាយនាយ, គ្រូអាចារ្យ, មាតាបិតា ... ។ ចំពោះព្រះមហាក្សត្រិយ៍ និងក្សត្រិយ៍តាំងក្រុម នោះបើបណ្ដាសាមញ្ញជនជាពលរដ្ឋ ត្រូវការគាល់ថ្វាយសេចក្ដីផ្សេង ៗ ក្ដី ឬបានទទួលព្រះករុណាពីម្ចាស់ផែនដីក្ដី ព្រះបន្ទូលក្សត្រិយ៍តាំងក្រុមក្ដី ត្រូវចូលទៅជិតហើយថ្វាយបង្គំ រួចអង្គុយ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ LIBRARY BUDDHIST INSTITUTE

ឲ្យរាបទាបល្អសមថ្វាយសេចក្ដីតាមហេតុរឿង (នៅលើព្រះមហាប្រាសាទ ឬលើដំណាក់) ។ បើប្រសិនជានៅទីសួនឧទ្យាន ក៏ត្រូវអង្គុយលើចុងជើងទាំងពីរ (ស្ទើរតែប្រះហាង) កែងដៃទាំងពីរសង្កត់លើភ្លៅ លើកចុងដៃឡើងផ្គងថ្វាយបង្គំ ឱនក្បាលបន្តិច រួចទើបថ្វាយសេចក្ដីតាមដំណើរ ។ យើងជាពលរដ្ឋ មិនត្រូវស្រែកថ្វាយសេចក្ដីពីចម្ងាយឲ្យសោះ ជាដាច់ខាត ត្រូវតែចូលទៅជិត អង្គុយថ្វាយបង្គំសិន សឹមថ្វាយសេចក្ដីតាមការ ។

មន្ត្រីក្ដី អាណាប្រជារាស្ត្រក្ដី កាលចូលគាល់ព្រះរាជា ហើយទ្រង់ព្រះរាជទានព្រំ ឬ កន្ទេលជាទីបង្គុយ យើងត្រូវអង្គុយបត់ជើង កែងដៃទាំងពីរសង្កត់លើភ្លៅ ដៃប្រណម្យ ឱនក្បាលបន្តិច ហៅថា អង្គុយម៉ប ទើបសមរម្យ ។

លក្ខណៈអង្គុយនៅមុខអ្នកធំ គឺនៅចំពោះព្រះករុណាព្រះមហាក្សត្រិយ៍ជាដើម តទៅមន្ត្រី និងបុគ្គការី ត្រូវអង្គុយឲ្យរាបរយជាដរាប ។

មិនត្រូវអង្គុយប្រះហាង គងជើងពែនភ្នែនបញ្ឈរជង្គង់ឲ្យសោះ ព្រោះជាអំពើទាស់នឹងច្បាប់សំរាប់ស្រុកដែលមានទម្លាប់ទំនៀម ប្រើឲ្យគោរពប្រតិបត្តិ ក្សត្រិយ៍ មន្ត្រី និងបុគ្គការី

ត្រូវអង្គុយបត់ជើង ហើយកុំច្រត់ដៃចំហៀងខ្លួនក្ដី ទៅមុខក្ដី ទៅក្រោយក្ដី ជាដាច់ខាត ។ ចុះដៃទាំងពីរត្រូវទុកដាក់ទៅត្រង់ណា ? ត្រូវផ្គុំគ្នាដាក់លើភ្លៅនៃជើងដែលយើងបត់ពីលើ ។

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY



បើរួយបង្គុយត្រូវប្រែជើងបត់ទៅម្ខាង នោះមានបែបយ៉ាងឲ្យប្រែឲ្យល្អមើលទៀត មិនឲ្យគ្គង មិនឲ្យឃើញចុងជើងចែងាង ៗ នោះត្រូវទុនខ្នងទៅមុខកែងដៃតាំងពីសន្ទត់លើភ្លៅ បង្ហើបបង្គុយបន្តិចឡើង ទើបដោះជើងត្រឡប់ទៅម្ខាងបានស្រួល ហើយរៀបបង្គុយជាថ្មី ៗ

របៀបប្រែបង្គុយផ្លាស់ជើងនេះ មិនត្រូវផ្លាស់ពីខាងមុខទេ ។ គេសំគាល់ថា បើនរណាប្រែបង្គុយផ្លាស់ជើងពីខាងមុខ អ្នកនោះជាមនុស្សមិនដឹងខុសត្រូវ មិនស្គាល់គួរសម មិនចេះគោរពកិច្ច ឬ គេពាត់ឲ្យឈ្មោះថាជាមនុស្សព្រៃហើន ៗ

ដែលលើកយករបៀបអង្គុយរាបគាល់ព្រះមហាក្សត្រិយ៍ មកអធិប្បាយជូនជាគំរូយ៉ាង ដូចមានខាងលើនេះ ក៏ប៉ុន្តែត្រូវកែបន្តិចតទៅទៀត សំរាប់អង្គុយ នៅចំពោះព្រះសង្ឃ - មន្ត្រីធំ - តូច នាយចៅហ្វាយនឹងបុព្វការី ៗ

បើយើងអង្គុយរាបនៅចំពោះព្រះភក្ត្រស្តេចសង្ឃ ដែលព្រះមហាក្សត្រិយ៍លើកដំកើងឡើងឲ្យមានព្រះជាតិជាស្តេច ដូចសម្តេចព្រះសង្ឃរាជ (ទៀង) នឹងសម្តេចព្រះសុគន្ធាធិបតី (ប៉ាន) នោះលក្ខណៈអង្គុយគាល់ក៏ត្រូវប្រើបែបអង្គុយគាល់ព្រះមហាក្សត្រិយ៍ដែរ ៗ សូម្បីតែពាក្យសំដីក៏ត្រូវប្រើពាក្យក្នុងព្រះរាជសព្ទទាំងអស់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

បើអង្គុយនៅចំពោះព្រះសង្ឃក្ដី - មន្ត្រីធំ - តូចក្ដី - នាយចៅហ្វាយក្ដី-បុគ្គការីក្ដី ត្រូវប្រើលក្ខណៈឲ្យបានកបរយតាំងជើង - ដៃ តាំងផ្លាស់ជើង-ផ្លាស់ដៃ ប៉ុន្តែមិនត្រូវម៉ប់ដូចអង្គុយគាល់ព្រះមហាក្សត្រិយ៍និងក្សត្រិយ៍តាំងក្រុមទេ ។ អង្គុយត្រង់ខ្លួនបានហើយ ។

## អង្គុយលើកៅអី

តាមរបៀបអឺរ៉ុប អង្គុយកៅអីហើយគងជើងឬក្រពាត់ជើងក៏រាប់ទុកជាកិច្ចគោរព ១ ដ៏គួរសមល្មមមិនរើសមុខថាធំថាតូចថាស្រីថាប្រុសថាចាស់ថាក្មេងទេ ។ មិនតែប៉ុណ្ណោះកិច្ចគោរពគួរសមយ៉ាងធំគេរៀបស្ត្រីឆ្លាស់គ្នានឹងបុរសទៀតផង ដើម្បីបង្ហាញសេចក្ដីលើកតំកើងយ៉ាងស្និទ្ធស្នាល ។

តាមទម្លាប់ទំនៀមខ្មែរក៏រាប់អានកៅអីជាទីបង្គុយរបៀប១មែនពិតដែរ តែគារវកិច្ចចំពោះអ្នកធំនិងស្រីនៅប្រកាន់ ពុំទាន់ឃ្លាតចាកទម្លាប់ទំនៀមចាស់នៅឡើយទេ ។ មិនត្រូវអង្គុយគងជើងព័ទ្ធជើងទេ និងរៀបរបៀបអង្គុយគាល់ព្រះមហាក្សត្រិយ៍បន្តិចជាគំរូដូច ។

១.— បើយើងឡើងក្រាបបង្គំគាល់ផ្ទាល់ព្រះមហាក្សត្រិយ៍ហើយព្រះអង្គទ្រង់ព្រះមេត្តាបដិសណ្ឋារៈ ទទួលដោយព្រះរាជទានកៅអីអង្គុយនោះ តាំងពីក្សត្រិយ៍ថ្នាក់ដែលទាបចុះមកក្ដី នាម៉ឺនសព្វមុខមន្ត្រីរាជបណ្ឌិតក្ដី ត្រូវលុតជង្គង់ថ្វាយបង្គំ ឬបន្ទន់ខ្លួនថ្វាយបង្គំទទួល សឹមឡើងអង្គុយ ។

www.budinst.gov.kh www.elibraryofcambodia.org

អង្គុយហើយត្រូវរៀបចំខ្លួនឲ្យសមរម្យ គឺដាក់ជើងទាំងពីរឲ្យរួមជិតទឹមគ្នា (កុំយះកន្ទួក) ដៃទាំងពីរប្រណម្យដាក់លើភ្លៅ ឱនក្បាលបន្តិចចុះ សឹមថ្វាយសេចក្តីផ្សេង ៗ ។

២.– បើទៀនក្រាបបង្គំគាល់ជាផ្លូវការ ដូចជាក្នុងព្រះរាជពិធីផ្សេងៗ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ដោយប្រោសព្រះរាជទានកៅអីអង្គុយដែរ នោះរបៀបក៏ស្រដៀង ៗ គ្នា គឺថាជើងទាំងពីរត្រូវតែរៀបឲ្យស្រួល មិនត្រូវសណ្តូកទៅមុខខ្លួនឲ្យត្រង់ មិនត្រូវផ្អែកទ្រេតទៅក្រោយ ។ បើជាពិធីចំរើនព្រះបរិត្ត ដៃទាំងពីរត្រូវសំពះលោក មិនត្រូវលើកដៃទៅពាក់លើខ្នងកៅអី ។ យ៉ាងនេះទើបសមរម្យជាអ្នកគោរពប្រណិប័តន៍ព្រះមហាក្សត្រិយ៍ តាមបែបផែនបុរាណរបស់ត្រកូលខេមរជាតិ ។

ប្រមូលសេចក្តីទាំងអស់ទៀងអំពីលក្ខណៈអង្គុយរាបក្តី កៅអីក្តី ត្រូវរៀបចំខ្លួនប្រាណឲ្យបានស្រួលបួលកុំច្រវេងច្រវាងច្រងេងច្រងាង ... ត្រូវដាក់ជើងដាក់ដៃឲ្យស្រួលឲ្យសមតាមសុភាពជាអ្នកមានត្រកូល - មានពូជពង្សថ្លៃថ្នូរ ។

*

*   *

## គោរពចំពោះស្ត្រីនិងមនុស្សចាស់

ក្នុងសាកលលោកទាំងមូល ធម្មជាតិបុរសរមែងបំពេញការកិច្ចឲ្យបរិបូណ៌ចំពោះស្ត្រី ៗ ទៅតាមរថឈ្នួល ដូចជារថភ្លើង រថយន្ត

www.budinst.gov.kh www.elibraryofcambodia.org

រថក្រាវៃ...។ល។ តាមកប៉ាល់ធំ-តូច ទូកចំឡង ...។ល។ ទៅទីប្រជុំទាំងឡាយ ទាំងពួង លើកតែបុគ្គលដែលបង់លេខទិញដាច់ថ្លៃកន្លងពេលនោះ ។ (ដូចមើលកុន-ល្ខោន) ។ បើមានស្ត្រីមកដល់ក្រោយហើយរកកន្លែងអង្គុយគ្មាន នោះបុរសដែលក្មេងជាងគេ ត្រូវគោរពស្ត្រីសំដែងសេចក្ដីគួរសមក្រោកឈរឡើង បន្ទូវ៉ាតាផ្ដើមពីសាអញ្ជើញស្ត្រីនោះឲ្យអង្គុយកន្លែងខ្លួនថា "សូមអញ្ជើញអ្នក-នាង-ម៉ែ-យាយ...មកអង្គុយកន្លែងខ្ញុំចុះ ។ កិច្ចនេះមិនចំពោះតែត្រង់រូបស្ត្រីទេ ប្រសិនបើមានចាស់ជរាគ្រាំគ្រាណាស់ហើយ ។ គ្មានកន្លែងអង្គុយ បុរសដែលក្មេងនៅមានកំឡាំងឈរបាន គប្បីប្រណីដល់មនុស្សចាស់ ដំកបអញ្ជើញគាត់ឲ្យមកកាន់កន្លែងយើង ដោយសេចក្ដីមេត្រីរាប់អានទុកដូចជាជីតារបស់យើង ។ យ៉ាងនេះគេសន្មតថាយើងមានធម៌គោរពចាស់ទុំនឹងស្ត្រីពេញបរិបូណ៌ ។

*

*   *

## ចំពោះព្រះសង្ឃ

កិច្ចគោរពព្រះសង្ឃតាមរទេះ-ទូក-កប៉ាល់...។ល។ ក៏មិនប្លែកពីគោរពមនុស្សចាស់នឹងស្ត្រីឡើយ ។ ប៉ុន្តែត្រូវដឹងថាគ្រហស្ថទាំងអស់គ្នាត្រូវគោរពព្រះសង្ឃទាំងអស់អង្គដែលយើងឃើញថាលោកគ្មានទីគង់

www.budinst.gov.kh www.elibraryofcambodia.org

នោះទោះស្ត្រីក្តី បុរសក្តី គប្បីក្រោកឈរយកកន្ទេលប្រគេនលោក ។ ត្រង់នេះ ត្រូវបុរសបំពេញកិច្ចនេះមុនស្ត្រី លុះត្រាតែអស់បុរសក្នុងទីនោះហើយ ទើបត្រូវស្ត្រីដែលនៅក្នុង នៅមានកំឡាំងឈរបានយូរបំពេញកិច្ចគោរពនេះតទៅទៀតជាលំដាប់ ។

ចុះបើព្រះសង្ឃនិងព្រះសង្ឃដូចគ្នា នោះខ្ញុំមិនអាចនឹងអធិប្បាយបានឡើយ ដោយបព្វជិតមានក្រិត្យវិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកមកស្រាប់ហើយ ។

*

* *

## អង្គុយក្នុងរថ

នឹងលើកយករថយន្តមកអធិប្បាយ ជាបែបផែនដូចជាគំរូពីទីអង្គុយក្នុងរថនេះ ។

រថយន្តដែលជាយានសំរាប់ផ្លាស់ខ្លួន រមែងមានទីអង្គុយពីរសន្លាក់ជាប់ពីគ្នាមុខក្រោយ អាចឲ្យយើងសំគាល់បានថាខាងមុខទន្ទឹមនឹងអ្នកបរនោះ ចាត់ជាទីបន្ទាប់ ខាងក្រោយចាត់ជាទីខ្ពស់ ។ ដូច្នេះគេគប្បីសំគាល់បានថា អ្នកធំ ឬអ្នកម្ចាស់រថនេះតែងតែអង្គុយខាងក្រោយ អ្នកតូចតែងតែអង្គុយខាងមុខជាមួយនឹងអ្នកបរជាទម្លាប់ ១ តែយ៉ាងនេះក៏មិនទៀងទៀត ។ ត្រូវចាត់របៀបដូចមានតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

១.– បើប្រសិនគេឲ្យរថយន្ត១ ទៅទទួលនិមន្តលោកសង្ឃពីវត្តមកផ្ទះគេ, ព្រះសង្ឃគប្បីនិមន្តលោកគ្រូដែលចាស់វស្សា ដូចជាលោកគ្រូចៅអធិការក្តី ឬគ្រូសូត្រក្តី ឬព្រះរាជាគណៈឋានានុក្រមក្តី ឲ្យគង់ខាងក្រោយ លោកដែលខ្ចីវស្សាដែលគ្មានយសសក្តិ ត្រូវគង់ខាងមុខទើបគួរ ។ នេះនិយាយអំពីរថយន្តតូចៗ (រថគឹង) ។ បើជារថធំ កាមីញ៉ុងវិញដែលមានចំណុះច្រើន នោះត្រូវរៀបលោកគ្រូធំៗ ឬ ចាស់ៗ មកគង់ជាមួយនឹងអ្នកបរខាងមុខវិញ ដាក់លោកអណ្តាប់មកខាងក្រោយវិញតាមលំដាប់ទើបគួរ ។

២.– បើអ្នកធំលោកហៅឲ្យយើងជិះរទេះជាមួយនឹងលោក យើងគប្បីជិះទន្ទឹមនឹងអ្នកបរ លើកតែលោកហៅយើងទៅអង្គុយជិតលោក នោះទើបគប្បីទៅបាន បើត្រឡប់ជាយើងមានរទេះ ហើយអញ្ជើញលោកអ្នកធំវិញនោះគប្បីប្រើរបៀបតែមួយ តែត្រូវយើងជាម្ចាស់រទេះបើកទ្វាររទេះអញ្ជើញលោកឲ្យឡើងមុន ។

៣... អញ្ជើញមិត្តភក្តិសក្តិស្មើគ្នាឲ្យជិះរទេះជាមួយ បើតែពីរអ្នកនឹងយើង នោះត្រូវអង្គុយទន្ទឹមគ្នាខាងក្រោយ បើយើងបររទេះខ្លួនយើងត្រូវអង្គុយទន្ទឹមគ្នាខាងមុខ ។

៤.— ត្រូវកុំភ្លេចថាយើងជាម្ចាស់ផ្ទះ ត្រូវបើកទ្វារផ្ទះអញ្ជើញភ្ញៀវឲ្យឡើងអង្គុយមុន តាមកន្លែងដ៏សមគួរអស់ហើយ បិទទ្វារផ្ទះឲ្យមាំទាំហើយ សឹមយើងឡើងទៅជាក្រោយ ។

៥.— បើទៅហ្វាយនាយ ប្រើយើងទៅណាមកណា ហើយបង្គាប់ថា ឲ្យយករបស់នេះលោកជះជូនទៅ នោះយើងមិនត្រូវទៅអង្គុយទន្ទឹមនឹងកន្លែងដែលលោកធ្លាប់អង្គុយ យើងត្រូវអង្គុយនៅទាបផ្លាប់ ទន្ទឹមជិតអ្នកបរ លើកតែនេះដែលមានកន្លែងតែ ១ ឬតែ ពីរ ប៉ុណ្ណោះ ។

*

* *

## វគ្គិយាបថទី ៣

## ឈរ

ឈរជាឥរិយាបថទី ៣ នៃជម្នាតិមនុស្សដែលកាលនៅជាទារក មាតាបិតាបង្ហាត់បង្ហាញឲ្យរៀនឈរមុនរៀនដើរ ក្រោយពេះអង្គុយ ។

ដល់យើងបានចំរើនធំឡើង មានវ័យជាបឋម មាតាបិតានឹងគ្រូអាចារ្យបានហ្វឹកហ្វឺនប្រដៅឲ្យដឹងខុសត្រូវ នឹងគួរសមគងឥរិយាបថទាំង ៤ ទៀត ។

ឥរិយាបថឈរនេះ ក្នុងត្រកូលដែលធ្លាប់មានសុខភាពរៀបរយល្អ ប្រដៅកូនចៅថា:

បើម្ដាយ-ឪពុក-ជីដូន-ជីតា-គ្រូអាចារ្យ អង្គុយកបហើយហៅកូនចៅ នឹងសិស្សឲ្យចូលមកជិតក្ដី ឬកូនចៅ សិស្សណាមានការចូលទៅជិតទីដំកបការផ្សេង ៗ ក្ដី មិនត្រូវឈរនិយាយ ទោះជាយកវត្ថុទៅជូនក៏មិនត្រូវឈរហុចដែរ ។

តែបើលោកអង្គុយពបទៅលើផ្ទះ ឬលើគ្រែដែលជាសេនាសនៈខ្ពស់ជាងទៅហើយ យើងនៅទីទាបជាង គប្បីឈរនិយាយបានមិនជាការធ្ងន់ទេ ក៏ប៉ុន្តែត្រូវបន្ទន់ខ្លួនបន្តិច ដើម្បីសម្ដែងគារវកិច្ចគោរពបូជាការឲ្យបរិបូណ៌ ។

ចំណែកខាងគារវកិច្ចចំពោះខត្តិយត្រកូល មានព្រះមហាក្សត្រិយ៍ជាដើម ការឈរនិយាយថ្វាយសេចក្ដីផ្សេង ៗ នោះខ្ញុំបានអធិប្បាយហើយក្នុងឥរិយាបថអង្គុយ ។

*

* *

## ឈរនៅទីប្រជុំ

មានកាលនៅទីប្រជុំអ្វីមួយ គេឈរផ្តុំប្រជុំគ្នាជាវង់ ដោយពួក ដោយក្រុម ដើម្បីសន្ទនានោះអ្នកទាំងឡាយដែលឈរក្នុងវង់ ត្រូវរំពៃប្រយ័ត្ន

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងគារវកិច្ចនៃឥរិយាបថដែលឈរនោះ គឺត្រូវកុំឈរប្រកិតជិតលោកដែលមានយសសក្តិធំជាងខ្លួន ឬលៀនលយចូលទៅទន្ទឹម ៗ មិនតែប៉ុណ្ណោះទេ ត្រូវកំរិតទាំងជើងដៃទៀតផង ៗ មិនត្រូវយកដៃច្រត់ចង្កេះ លូកក្នុងហោប៉ៅខោ - ហោប៉ៅអាវ - បោះជើងទៅមុខ - ទៅក្រោយ ចំទេង កន្ទេក យោលខ្លួនប្រាណឡើយ ព្រោះជាការខ្វះគួរកិរិយាគោរពដល់ចាស់ព្រឹទ្ធាចារ្យនឹងមន្ត្រីធំ តូច ដែលរួមប្រជុំជាមួយផង ៗ

ចុះបើយើងឈរប្រជុំជាមួយនឹងមិត្តស្និទ្ធរបស់យើងនោះ កិច្ចគារវៈជាធម្មតា តាមសមគួរមើលដល់ផ្នែកអ្នកដទៃឲ្យផុតសេចក្តីរិះគន់ ៗ

*

* *

## ឈរជិតអ្នកអង្គុយ

នៅទីណាក៏ដោយ បើមានគេអង្គុយកាបក្តី អង្គុយកៅអីក្តី យើងមិនត្រូវទៅឈរជិតហួសប្រមាណទេ គឺឈរស្ទើរតែជាន់គេ ឬក៏សដៃលើកដាក់ចុះឡើង ស្ទើរតែប៉ះខ្លួនប្រាណគេ យ៉ាងនេះត្រូវប្រយ័ត្នឲ្យណាស់ ព្រោះមានកាលបណ្តាលទៅជាជម្លោះប្រមាថគ្នាក៏មាន វាយតប់គ្នាក៏មាន ៗ តែបើយើងភ្លេចស្មារតី លើកដៃទៅប៉ះអ្នកនៅឈរជិតខាងគ្នាដោយឥតមានចំណង់ នោះយើងគប្បីបន្ទូរវាចាថា "សូមទោស" ដោយសំឡេង

www.budinst.gov.kh www.elibraryofcambodia.org

ទន់សុភាព ។ អ្នកដែលត្រូវគេប៉ះពាល់នោះគប្បីអត់នូវទោសនោះឲ្យអ្នកដែលសូមទោស ដោយប្រើឫកពាល្អមិនទទឹងសំបារ មិនប្រើកិរិយាកញ្ចុកកញ្ចូវឡើយ ។

*

* *

## ក្រោកឈរ

កាលយើងនៅសាលារៀន លោកគ្រូយើងប្រដៅឲ្យក្រោកឈរគំនាប់គួរសមចំពោះភ្ញៀវដែលចូលមកក្នុងបន្ទប់យើងរៀន មានលោកចាងហ្វាងសាលាជាដើម ។ រាល់ថ្ងៃដែលយើងចូលទៅរៀន យើងត្រូវឈរគោរពលោកគ្រូយើងសិន ទាល់តែលោកគ្រូឲ្យអង្គុយទើបហ៊ានអង្គុយ ។ ដល់ពេលចេញពីរៀនទៀត លោកគ្រូយើងបង្គាប់ឲ្យក្រោកឈរសិន ទើបឲ្យចេញទៅក្រៅ ។ គារវៈនេះជាកិច្ចប្រសើរល្អណាស់ សំរាប់បង្ហាត់សិស្សានុសិស្សឲ្យចេះគោរពចាស់ គោរពគ្រូអាចារ្យ គោរពអ្នកធំ កាលមកដល់ទីកាលត្រឡប់ទៅវិញ ។

ដូច្នេះ កិច្ចក្រោកឈរគោរពនេះមានតទៅទៀតជាច្រើនប្រភេទ ច្រើនបណ្ណាន ។

*

* *

## ទៅក្នុងកន្លែងធ្វើការ

នៅក្នុងកន្លែងធ្វើការ ក៏ដូចនៅកន្លែងរៀន ។ អ្នកធ្វើការទាំងអស់សុទ្ធតែអង្គុយនៅកៅអីធ្វើការ បើកាលណាចៅហ្វាយនាយចូលមកក្តី ឬមានអ្នកធំឯណាមួយចូលមករកចៅហ្វាយនាយយើងក្តី យើងគប្បីក្រោកឈរគោរពដោយបន្ទន់ខ្លួនឱនក្បាល ឬលើកដៃសំពះតាមកាលគួរ ។

*

* *

## នៅទីប៉ាឆា

យើងពុំបានទៅហែសពនឹងគេទេ យើងទៅនៅចាំមុខឯទីប៉ាឆាឬនៅវត្ត ។ ម្ចាស់សពរៀបកៅអីទុកបំរុងទទួលភ្ញៀវនឹងញាតិមិត្ត ។ កាលណាក្បួនដង្ហែសពទៅដល់ យើងត្រូវក្រោកឈរគោរពសព លុះត្រាតែគេដាក់កល់ស្រេចនៅលើជើងថ្ករទើបគប្បីអង្គុយចុះទៅវិញ ។ ដល់ពេលព្រះសង្ឃនិមន្តមកបង្សុកូលទៀត យើងរាល់គ្នាត្រូវក្រោកឈរគោរពព្រះសង្ឃទៀត លុះត្រាតែលោកស្រូតចប់និមន្តទៅវិញ ។

បើមានព្រះមហាក្សត្រិយ៍ស្តេចយាងទៅផងជាព្រះរាជាធិបតី ពេលព្រះអង្គស្តេចយាងទៅព្រះរាជទានផ្កាខ្លឹមចន្ទន៍ដល់សព នោះបណ្ដាជនា-

ខុដននៅទីនោះទាំងប៉ុន្មានត្រូវក្រោកឈរគោរពទាំងអស់គ្នា[១] លុះត្រាតែស្តេចយាងត្រឡប់មកគង់នៅទីប្រថាប់វិញ ។

នៅពេលដែលព្រះមហាក្សត្រិយ៍ព្រះរាជទានភ្លើងសពនេះទៀត ឬបើជាសពធម្មតាដែលគ្មានព្រះមហាក្សត្រិយ៍ កិច្ចរំលាយសពធ្វើតាមទម្លាប់ទំនៀមប្រពៃណីពីបុរាណមក គឺមានអាចារ្យយោគីខាងមុខ អ្នកគុក ៤ ខាងក្រោយដើរបណ្ដោយគ្នាប្រទក្សិណសពហើយធ្លុលភ្លើង នោះយើងកល់គ្នាគប្បីក្រោកឈរគោរពជូនដំណើរសពជាបច្ឆិមកិច្ច ហើយគប្បីនៅស្ងៀមស្ងឹងស្ងាត់ ដាក់មុខចុះបន្តិច ពិចារណានូវមរណស្សតិ លើកនូវសេចក្តីស្លាប់តាមពុទ្ធោវាទដែលមានច្រើនបែបច្រើនយ៉ាងណាស់ ។

ឈរនេះត្រូវប្រហែលជា ៥ នាទី នាឡិកា រួចទើបលំអង្គុយទៅវិញ ។ ជួនកាលគេយកតាមភ្លេងដែលលេងជូនដំណើរភ្លើងនោះជាកម្រិតពេលនៃកិច្ចឈរគោរពនេះ ។

*

* *

## ឈរលេង

ដំណើរឈរលេង ត្រូវឲ្យពិចារណាថា ទីកន្លែងដែលយើងឈរតើជាទីមានទំនាស់ឬទេ? បើឃើញថាមិនទំនង ត្រូវរកកន្លែងដទៃទៀតឲ្យជាទីដ៏សមគួរ ។

---

១ លើកតែអ្នកអង្គុយរាបផ្ទាល់កន្ទេល ។

មិនត្រូវឈរលេងនៅកណ្ដាលថ្នល់ នៅផ្លូវបត់កាច់ជ្រុង នៅមាត់ច្រកដែលជាទីចង្អៀត នៅមាត់ទ្វារ មាត់ជណ្ដើរ ដែលនាំឲ្យទើសទែង ដល់អ្នកគោចរ ។

*

* *

## ឈរគោរពទង់ជាតិនិងភ្លេងជាតិ

កាលបើយើងដើរនៅថ្នល់ ឬនៅទីណាមួយ នៅប្រទះប៉ះលើពេល ដែលគេកំពុងធ្វើពិធីបង្ហូតទង់ជាតិ មានផ្លុំត្រែក្ដី ឥតផ្លុំត្រែក្ដី យើងគប្បីឈប់ដើរ ឈរទឹមជើង សំយុងដៃទាំងពីរ ងើបងើយក្បាលឡើង ភ្នែកសំឡឹងទៅទង់ជាតិដែលកំពុងបង្ហូតនោះ រួចហើយសឹមដើរទៅទៀត ។

ចំពោះភ្លេងជាតិ (នគររាជ) ក៏ដូចគ្នា បើយើងដើរក្ដី នៅលើរថយន្តក្ដី លើទោចក្រយានក្ដី... ។ល។ បើទៅប្រទះគេកំពុងលេងភ្លេងជាតិក្នុងពិធីអ្វីមួយ ត្រូវតែប្រើកិរិយាឈប់ឈរគោរពឲ្យអស់រយៈភ្លេង សឹមតដំណើរទៅទៀត ។

កិច្ចឈរគោរពទង់ជាតិនិងភ្លេងជាតិនេះ ប្រសើរណាស់ សំរាប់ជនជាតិនីមួយ ៗ ព្រោះក្នុងសាកលលោកនេះ គេតែងតែគោរពទង់ជាតិនិងភ្លេងជាតិគេដោយស្មោះអស់ពីចិត្តគ្រប់ ៗ គ្នា ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## ឥរិយាបថទី ៤

## ដើរ

ដើរជាឥរិយាបថ ទី ៤ មានលក្ខណៈឲ្យជាបែបបទទៅជាទម្លាប់ទំនៀមសម្រាប់អ្នកស្រុកប្រតិបត្តិដែរ ឲ្យត្រឹមត្រូវតាមគន្លងប្រពៃណី ។

ដើរមានច្រើនប្រភេទ គឺដើរហែជាក្បួនជាផ្លូវការ, ដើរហែជាក្បួនធម្មតារបស់សាមញ្ញជន (មានធ្វើបុណ្យជាដើម), ដើរហែក្សត្រិយ៍ខត្តិយវង្សផ្ទាល់ព្រះអង្គ, ដើរតាមមន្ត្រីធំ-តូចផ្ទាល់ខ្លួន ដើរតាមមាតា-បិតា ជីដូនជីតា គ្រូបាអាចារ្យចាស់ទុំ, ដើរជូនដំណើរភ្ញៀវ... ។ល។ ត្រូវបំពេញការកិច្ចនេះឲ្យគ្រប់បរិបូណ៌នឹងតាមទម្លាប់ទំនៀមខ្មែរ ។

*

*  *

## ដើរក្នុងក្បួនហែ

ក្បួនហែឯណាមួយ ដែលមានរបៀបរៀបតាមរយៈតាមសង្កាត់ អ្នកទៅជួយឬទៅគួរសមក្នុងបុណ្យនោះ មិនគប្បីនឹងចូលទៅដើរលាយឡំ ឲ្យខូចរបៀបក្បួនរបស់គេឡើយ ។

ឧបមាដូចហែសព យើងគប្បីចូលចិត្តឲ្យច្បាស់ថា យើងជាអ្នកហែក្នុងក្បួនដែលគេចាត់ ឬ យើងជាភ្ញៀវទៅជូនដំណើរសព ។

www.budinst.gov.kh www.elibraryofcambodia.org

បើយើងជាអ្នកហែក្បួនរបៀបក្បួន យើងត្រូវស្ដាប់បង្គាប់អ្នករៀបក្បួន គេឲ្យយើងដើរត្រង់ណា ត្រូវយើងដើរត្រង់ណោះឲ្យបានរៀបរយ ។

ចុះបើយើងជាភ្ញៀវ យើងជាអ្នកជូនដំណើរសព ចេញចាកពោលទីលំនៅ ទៅកាន់ទីសូសានស្ថានស្មូត ឬទៅកាន់ទីប៉ាឆា ។ បើដូច្នេះហើយអ្នកជូនដំណើរ ត្រូវដើរតាមក្រោយសពទើបគួរ ។

អ្នកដែលត្រូវដើរពីក្រោយសព គប្បីរៀបជាលំដាប់ដូចតទៅនេះ៖

១.- ស្ត្រី

២.- បុរស

ស្ត្រីដែលជាកូនចៅទាំងសាច់សាលោហិតរបស់សព ត្រូវដើរជាប់នឹងសពពីខាងក្រោយ រួចតទៅត្រូវស្ត្រីដែលជាមិត្តជាភ្ញៀវ ។

អស់លោកប្រុស ៗ ក៏មានរបៀបដូចគ្នានឹងលោកស្រី ៗ ដែរ តាមលំដាប់ញាតិមិត្តនឹងភ្ញៀវ ។

(ក្នុងត្រកូលខ្លះគេឲ្យកូនប្រុសដើរមុខសព កូនស្រីដើរក្រោយសព)

*

* *

www.budinst.gov.kh www.elibraryofcambodia.org

# ដើរជាមួយព្រះសង្ឃ

ព្រះសង្ឃជាទីគោរពរបស់គ្រហស្ថគ្រប់ទីគ្រប់តំបន់ ។ ដូច្នេះបើយើងជាគ្រហស្ថដើរជាមួយភិក្ខុសាមណេរ នោះយើងមិនត្រូវដើរមុខ ឬទន្ទឹមស្មើនឹងលោកទេ ទោះជាបិតាក្តី ក៏ពុំគប្បីឡើយ ។

តែមានកាលខ្លះ លោកអនុញ្ញាតឲ្យគ្រហស្ថដើរមុខបាន ។ ព្រះធម្មកថិកនិមន្តទៅសម្តែងធម៌នៅគេហស្ថានឧបាសក-ឧបាសិកា លោកតែងឲ្យក្មេងដែលលីគម្ពីរដើរមុខ ។ យ៉ាងនេះគេពុំសំគាល់ត្រង់ក្មេងនោះទេ គេសំគាល់យកព្រះធម៌ដែលនៅក្នុងគម្ពីរនោះ លើកដម្កល់ឡើងឲ្យធំជាងព្រះសង្ឃ ។ តែបើព្រះធម្មកថិកអង្គណាយល់ថាក្មេងជាសិស្ស ត្រូវតែដើរក្រោយលោកគ្រូ នោះឃើញថា ព្រះធម៌ដែលមានក្នុងគម្ពីរ មិនប្រសើរលើសលោកដែលចេះសំដែងធម៌ទេសនានោះឡើយ ។

លោកសន្តោសដល់អ្នកនាំផ្លូវទៀត អាចនឹងដើរមុខព្រះសង្ឃបាន ដោយសគ្រោះថាជាមគ្គុទ្ទេសក៍ ក៏ត្រូវតែត្រាយផ្លូវខាងមុខទើបស្រួលដំណើរ ។

⁂

⁂ ⁂

www.budinst.gov.kh www.elibraryofcambodia.org

## ដើរកាត់ហ្វូង

នៅទីប្រជុំនីមួយ ៗ ដែលមានមនុស្សអង្គុយដំកង់ ឬឈរផ្ដុំគ្នាជាវង់ ដោយពួកដោយក្រុម នោះអ្នកដើរទៅមក មិនត្រូវដើរកាត់ហ្វូងឲ្យសោះ ទោះបីគេឈរនិយាយគ្នាតែពីរនាក់ យើងក៏មិនត្រូវដើរកាត់គេទេ ត្រូវដើរចៀសគេចពីខាងក្រោយខ្នងគេ យ៉ាងនេះទើបសមជាអ្នកកាន់គារវកិច្ច ចំពោះមិត្រមនុស្សដូចគ្នា ។

*

* *

## កិរិយាដើរ

## កិរិយាដើរមានច្រើនលក្ខណៈ

១.– ដើរនៅនាមុខព្រះភ័ក្ត្រ ព្រះមហាក្សត្រិយ៍ ។ នោះបើព្រះអង្គគង់កប បណ្ដាខ្ញុំរាជការដែលនៅគាល់បំរើផ្ទាល់ព្រះអង្គដែលចូលថ្វាយវត្ថុជាដង្វាយ គេតែងតែដើរដំណើរទាបហៅថាដើរ " ទា " គឺដើរនឹងចុងជើងទាំងពីរ ក្បាលជង្គង់ ( ឆ្វេង ) ១ ដៃឆ្វេងប្រត់ ដៃស្ដាំកាន់អីកាន់ថ្វាយ ។ បើដើរចូលទៅដោយគ្មានកាន់អ្វីទេ នោះត្រូវផ្លាស់ឆ្វេងម្ដង ស្ដាំម្ដង ៗ របៀបដើរ " ទា " នេះ គេដើរពីចម្ងាយប្រហែល ៥ ម៉ែត្រ ចូលទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

បើនឹងវិលមកវិញ ក៏គោរដើរបែបនេះដែរ តែថយក្រោយឲ្យផុតចម្ងាយ ៤ ម៉ែត្រនេះ ទើបបង្វិលខ្លួនតាមធម្មតា ។

២.– ដើរជិតអ្នកធំ ឬ បុព្វការីជន ។

បើអ្នកមានបណ្ដាស័ក្តិ ឬ នាយចៅហ្វាយ មាតា បិតា គ្រូអាចារ្យ ចាស់ទុំ អង្គុយកបក្តី លើកៅអីក្តី យើងដើរទៅជិតគប្បីបន្ទន់ខ្លួនឱនបន្តិច ជាកិច្ចគារវៈចំពោះលោកទាំងនោះ នេះជាទម្លាប់ទំនៀមរបស់ខ្មែរជាតិ ពីបុរាណរៀងមក ។ តែបើយើងចូលក្នុងចំណោមបរទេស នោះគប្បីមើលតាមកាលៈទេសៈ ព្រោះដូចជា ថៃ - និងលាវក៏មានទម្លាប់ទំនៀមត្រូវៗគ្នានឹងខ្មែរដែរ, ក៏ឯជនប្រទេសអឺរ៉ុបវិញ នោះយើងគប្បីធ្វើតាមអារ្យធម៌គេ ដើម្បីកុំឲ្យឈ្លើយ ។

៣.– ដើរកន្លងគេ ។

យើងបានដឹងបានឃើញជាក់ថា ជនជាតិបារាំងក្តី ចិន យួនក្តី ឥតមានប្រកួតប្រកាន់ក្នុងដំណើរដើរកន្លងអ្នកដទៃឡើយ កុំតែដើរជាន់ ៗ

ចំណែកខ្មែរ - ថៃ - លាវ យើងប្រកាន់ណាស់ មិនត្រូវដើរកន្លងជើង - ដៃអ្នកដទៃឲ្យសោះ នេះជាច្បាប់ទម្លាប់មួយសំខាន់ណាស់ សំរាប់សាសន៍ទាំង ៣ នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ដំណើរដើរក្នុងនេះមានត្រណាមច្រើន ៖

ក)– គេមិនដើរកន្លងព្រះរូបព្រះពុទ្ធ ព្រះរូបម្ចាស់ផែនដី (ព្រះឆាយាលក្ខណ៍) រូបមាតាបិតា រូបគ្រូអាចារ្យ រូបព្រះចេតិយ និងរូបបុព្វការី ... ។ល។

ខ)– គេមិនដើរកន្លងគម្ពីរបាលី ដែលមានធម៌អាថ៌ ។

គ)– គេមិនដើរជាន់ឬកន្លងកន្លែងសំណឹងព្រះភិក្ខុសង្ឃ សាម-ណេរនេះ១ កន្ទេលពូកដែលជាដំណេកមាតាបិតា ជីដូន ជីតានេះ១ ។

ឃ)– គេមិនដើរជាន់ឬកន្លងព្រំចៀម ដែលជាទីគង់នៃព្រះមហាក្សត្រិយ៍នេះ១ ។

ង)– គេមិនដើរជាន់ឬកន្លងព្រំកំរាលដែលគេរៀបជាមង្គលសួស្តីនេះ១ (ដូចជាកន្លែងរៀបសំពះការអាពាហ៍ពិពាហ៍) ។

តែបើមានកិច្ចត្រូវកាត់ធ្លងទៅម្ខាង នោះត្រូវលាត់កំរាល ឬព្រំនោះឡើងហើយក៏កាត់ទៅទើបសមគួរ ។

ច)– នៅមុខព្រះពន្លា ដែលជាទីប្រថាប់នៃព្រះមហាក្សត្រិយ៍ ក្នុងពិធីអ្វីមួយ នោះបើព្រះមហាក្សត្រិយ៍ស្តេចយាងមកគង់ប្រថាប់នៅទីនោះហើយ បណ្តាពលរដ្ឋមិនត្រូវដើរកាត់ធ្លងពីម្ខាងទៅម្ខាងទេ បើយើងមានការត្រូវចាត់ចែងនូវកិច្ចផ្សេង ៗ គប្បីគេច្រកដើរចំហៀងឬពីក្រោយ ។

www.budinst.gov.kh www.elibraryofcambodia.org

តែបើគាល់ទីកន្លែងដើរមិនបាន ត្រូវដើរទៅហើយថ្វាយបង្គំសិន សឹមក្រោកដើរទៅទៀតទើបសមគួរ ។

១)- ដំណើរដើរទៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ មិនត្រូវបង់ប្រាយឲ្យសោះ ត្រូវតែផ្គុំដៃទាំងពីរពីខាងមុខ ហើយឱនក្បាលឲ្យទាបបន្តិចដើរទៅ លុះត្រាតែថយទៅទើបប្រើដំណើរដូចដើមវិញ ។

*

* *

## បង្វិលខ្លួន

នៅចន្លោះអង្គុយ-ឈរនិងដើរ នៅមានដំណើរបង្វិលខ្លួនជាកិរិយា-បថមួយទៀត ដែលយើងត្រូវបំពេញបន្ថែមឲ្យសមរម្យក្នុងការកិច្ច ។

យើងអង្គុយកៅអីនៅចំពោះមុខអ្នកធំនឹងបុគ្គលការីជាជនដែលយើងគប្បីគោរព បើយើងនឹងលាវិលវិញ ត្រូវក្រោកឈរឡើងធ្វើគារវកិច្ច ដោយសំពះលាម្តងទៀត ឬ ឱនក្បាលម្តងទៀតដើរថយក្រោយបានពីរ ឬ បីជំហានសឹមបង្វិលខ្លួន បែរមុខទៅរកទ្វារដែលត្រូវដើរចេញទៅ ។

ដំណើរបង្វិលខ្លួននេះ បើយើងចូលគាល់ព្រះមហាក្សត្រិយ៍នោះត្រូវប្រយ័ត្នកិរិយាបថនេះឲ្យមែនទែន, ទោះជាអង្គុយគាល់ក៏ដោយ

www.budinst.gov.kh www.elibraryofcambodia.org

កាលយើងក្រាបថ្វាយបង្គំលារូបហើយ ត្រូវថយក្រោយបានពីរឬបីជំហានសិន ទើបត្រូវបង្វិលខ្លួនហើយក្រោកដើរចេញទៅ ។

ដំណើរបង្វិលខ្លួននេះ មានឧទាហរណ៍មួយទៀតជាសំខាន់ណាស់ ៗ យើងទៅលេងផ្ទះគេ លាគេវិលវិញ ម្ចាស់ផ្ទះប្រកាន់ការគួរសមដោយគោរព ក៏ជូនដំណើរយើង ដល់មាត់ទ្វារផ្ទះក្តី មាត់ទ្វាររបងក្តី នោះទៅពេលចេញផុតទ្វារត្រូវបង្វិលខ្លួនបែរមុខទៅរកម្ចាស់ផ្ទះវិញ ហើយធ្វើគារវកិច្ចម្តងទៀតដោយសំពះឬងក់ក្បាល ។

ដំណើរបង្វិលខ្លួននេះមានលក្ខណៈមួយ ដែលយើងកុំគប្បីធ្វេសឲ្យសោះ កុំឲ្យភ្លាត់បាន គឺកុំបង្វិលខ្លួនបែរខ្នងទៅរកធំដែលនៅក្នុងទីប្រជុំ ។

ប្រៀបដូចអ្នករបាំ ដែលសំដែងរបាំនៅលើឆាក នោះតាមរបៀបរបាំអឺរ៉ុប គេបង្ហាត់ល្មោន គេមិនឲ្យបង្វិលខ្លួនបែរខ្នងទៅឲ្យអ្នកមើលទេ ទោះយ៉ាងណាក៏ដោយ ក៏ត្រូវតែបែរចំហៀងខ្លួនឲ្យស្រួល ។

អធិប្បាយប៉ុណ្ណោះក៏ល្មមលោកអ្នកស្តាប់បាន ល្មមចូលចិត្តបានក្នុងដំណើរបង្វិលខ្លួននេះ ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## ក្អក-កណ្តាស

នៅនាប្រជុំជំនុំ - តូចក្តី ដំណើរក្អក កណ្តាស ជាឧបស័គ្គឲ្យរំខាន ដល់អ្នកសម្តែងនូវសេចក្តីផ្សេង ៗ និងអ្នកស្តាប់ទាំងពួងក្នុងទីប្រជុំនោះ ។

បើក្អក - កណ្តាសកើតឡើងបន្តិចបន្តួចដោយឈ្ងក់ខ្យល់ ឬ ឈ្ងុល ច្រមុះនឹងក្លិនឬ ផង់ធូលី វត្ថុអ្វីមួយនោះ មិនជាការឲ្យរំខានដល់គេឯងផងទេ អាចនឹងទ្រាំខ្ទប់មាត់ខ្ទប់ច្រមុះទៅបាន ។ តែបើខ្ទប់មាត់ ខ្ទប់ច្រមុះហើយ ពុំស្រាកន្ត យើងគប្បីក្រោកចាកទីនោះសិន ចេញឆ្ងាយទៅរកឧបាយ បំបាត់រោគនេះសិនសឹមចូលមកវិញ ។ យើងត្រូវចាំថា បើក្អក កណ្តាស ត្រូវយកកូនកន្សែងខ្ទប់មាត់ ខ្ទប់ច្រមុះជាដរាប ប្រយោជន៍កុំឲ្យព្រួសខ្ទាំង កុំឲ្យចេញទឹកមាត់និងទឹកសម្បោរបាចព្រោះព្រាយសាចទៅលើគេ ឯងដែលអង្គុយជិតខាងផងគ្នា ។ យើងត្រូវកុំភ្លេចថា បើនឹងក្អកកណ្តាស ត្រូវបែរមុខចេញអំពីមុខគេ ឬត្រូវដើរចេញឲ្យឃ្លាតឆ្ងាយពីគេឯង ទៅ បន្ទោបង់នូវគ្រឿងកង្វក់គឺ កំហាក-ស្លេស្ម សម្បោរ-ទឹកមាត់ឲ្យអស់សិន ហើយជូតមាត់-ច្រមុះឲ្យស្អាតបាតសឹមវិលចូលមកកាន់ទីដើមវិញទើបសម គួរ ។

*

* *

## ខាក-ស្តោះ

រោគក្អក-កណ្តាសនេះរមែងមានការខាកស្តោះជាប់តមកជាលំដាប់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះតែខាកហើយត្រូវស្ដោះជាធម្មតា ។ ត្រូវស្ដោះដាក់កន្ថោរ ទៅទីណាដែលគេដាក់កន្ថោរទុកចាំរង់ឲ្យ ។ បើគ្មានកន្ថោរត្រូវស្ដោះដាក់ក្នុងកន្សែង (ហោប៉ៅ) រួចសឹមយកទៅដុសលាងជាក្រោយ ។

យើងមិនត្រូវខាកស្ដោះឲ្យសោះ ៖

១.– ទៅទីណាក៏ដោយដែលគេសំអាតល្អ ។

២.– ទៅលើវត្ថុក្ដារក្រាលផ្ទះ – សាលា ... ។ល។

៣.– ទៅជើងសសរនឹងជើងជញ្ជាំងផ្ទះ – សាលា ... ។ល។

៤.– តាមបង្អួចផ្ទះ – សាលា ... ។ល។ (ទៅដី) ខ្លាចក្រែងទៅលើគេដែលទៅខាងក្រោម ។

៥.– បើមានអ្នកឯណាមួយដើរមកប៉ះប្រទះមុខនឹងយើង ៗ ត្រូវបង្អង់ឲ្យគេដើរហួសទៅសិន ។

៦.– បើយើងឈរ ឬ អង្គុយនិយាយគ្នាតែពីរនាក់ក្ដី ច្រើននាក់ក្ដី ទៅមុខអ្នកទាំងនោះ ត្រូវបែរមុខចេញសឹមស្ដោះ ។

៧.– ទៅទីជិតខាងគេឯងដែលកំពុងបរិភោគអាហារ ។

៨.– ទៅភត្តាគារដែលជាទីប្រជុំជនច្រើន បរិភោគខាទនីយភោជនីយាហារ ។

ឯការខាក បើត្រូវការខានពុំបានដោយឃាត់ពុំឈ្នះត្រូវខាកតិច ៗ កុំឲ្យកើតខ្ពើមរអើមដល់គេឯង ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

# ស្ងាប

ស្ងាបជាកិរិយាដែលបើកមាត់ធំ ហើយដកដង្ហើមវែងបញ្ចេញខ្យល់មក ឮសូរហួម ៗ ។ ស្ងាបនេះយើងពុំមែនតែងធ្វើទេ គឺបណ្ដាលពីការនឿយហត់អស់កំឡាំង ហើយងងុយដេកក៏មាន បកពីអត់ងងុយក៏បាន ឬដល់ពេលងងុយតាមធម្មតាក៏មាន ។

មានកាលយើងងងុយពេក ស្ងាបទៅចេញទឹកភ្នែកទឹកសម្បោរផងក៏មាន ។

ដំណើរហាមាត់ស្ងាបឲ្យអស់ចំហជាកិរិយាមិនល្អមើល ថែមបន្លឺសូរហួម ៗ ទៀត ជាសព្ទមិនពិរោះស្ដាប់សោះ ។ ហេតុនេះ កាលណាយើងស្ងាបនៅទីណាក៏ដោយ សូម្បីនៅតែម្នាក់ឯង ក៏គប្បីយកកូនកន្សែង ឬយកដៃខ្ទប់មាត់ ដែលហានោះជាដរាបជាទម្លាប់ ដើម្បីកុំឲ្យធ្លាប់ភ្លេចខ្លួនទៅ ៗ ហាមាត់នៅកណ្ដាលប្រជុំជន ។

បើកាលណាយើងដឹងខ្លួនថា ចង់ស្ងាបហើយ យើងត្រូវប្រយ័ត្នរក្សាសតិប្រុងខ្លួនដឹងកុំឲ្យឮហួម ៗ ទឹងយកដៃ ឬកូនកន្សែង ខ្ទប់មាត់ ខ្ទប់មុខ ទឹងជូតមុខជូតភ្នែកឲ្យស្អាតវិញ ដូចដើម ។

*

* ✿

www.budinst.gov.kh www.elibraryofcambodia.org

## បង្គំ - សំពះ

ពាក្យ "បង្គំ" ជាគូនឹងពាក្យ "សំពះ" គឺអំពើគោរព ចំពោះគ្រប់អ្នកដែលគួរគោរព ។

"បង្គំ" នឹង "សំពះ" មានកិរិយាមិនដូចគ្នាទេ យើងត្រូវប្រយ័ត្នកុំឲ្យច្រឡំគ្នា ។ កិរិយា "បង្គំ" មានច្រើនបែប "សំពះ" ក៏មានច្រើនបែបដែរ ។

១.— "បង្គំ" ប្រើក្នុងព្រះពុទ្ធសាសនា សំរាប់និយាយថា "ថ្វាយបង្គំព្រះ" "ថ្វាយបង្គំលោកសង្ឃ"

របៀបថ្វាយបង្គំនេះ មានបែបផែនដូចមានតទៅ គឺអង្គុយបែ-ហោង ក្ដួយដៃទាំងពីរដាក់លើក្បាលជង្គង់ ចុងដៃផ្គុំគ្នាទាំងពីរលើកឡើងទៅប្រជុំចិញ្ចើម បើក្រាបចុះទៅ ត្រូវឲ្យក្បាលជង្គង់-ក្ដួយដៃ ក្បាលទូងឲ្យដល់កន្ទេល យ៉ាងនេះបានពេញលក្ខណៈ ហៅថា "ថ្វាយបង្គំព្រះថ្វាយបង្គំលោកសង្ឃ" ។ បើយើងអង្គុយបត់ជើងកបរិញ ក៏ត្រូវប្រើងទូងក្បាលឲ្យដល់កន្ទេល ដាក់ក្ដួយដៃទាំងពីរឲ្យដល់កន្ទេល ។

តែបើនៅទីដែលយើងអង្គុយពុំកើត នោះយើងគប្បីផ្គុំដៃទាំងពីរប្រណម្យលើកឡើងដាក់ដល់ប្រជុំចិញ្ចើម ទូងក្បាលបន្ទន់ខ្លួនទៅខាងមុខឲ្យល្មមសមគួរ យ៉ាងនេះគឺបរិបូណ៌ក្នុងគារវកិច្ច ថ្វាយបង្គំព្រះនឹងលោកសង្ឃ ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## ២.– ក្នុងពាក្យរាជស័ព្ទ

គេប្រើសំរាប់និយាយខាងក្សត្រិយ៍ខត្តិយត្រកូល ។ គេនិយាយថា "ក្រាបបង្គំគាល់ ឬក្រាបថ្វាយបង្គំគាល់" គឺចូលក្រាបថ្វាយបង្គំ ហើយអង្គុយគាល់ ។ "ក្រាបបង្គំទូល" គឺចូលក្រាបថ្វាយបង្គំទូលផ្ទាល់មាត់ ឬក្រាបទូលដោយលិខិត ។ "ថ្វាយបង្គំ ឬក្រាបថ្វាយបង្គំ" គឺសំពះ ឬក្រាបសំពះដោយគោរព ។

ក –) របៀបថ្វាយបង្គំព្រះមហាក្សត្រិយ៍និងក្សត្រិយ៍គ្រប់ព្រះអង្គ ។ ត្រូវអង្គុយលុតជង្គង់ លើកដៃប្រណម្យនៅដើមទ្រូងបន្ទន់ខ្លួនទន់ចុះទៅពាក់កណ្ដាល ដៃទាំងគូដាក់ដល់កន្ទួលហើយលើកឡើងទទួលក្បាលទៅប្រជុំចិញ្ចើម រួចងើបឡើងអង្គុយបែបតាមទម្លាប់ ។

(ត្រង់នេះ កុំឲ្យច្រឡំនឹងថ្វាយបង្គំព្រះនឹងលោកសង្ឃ)

បើទៅទីដីដែលយើងលុតជង្គង់ពុំកើតបានត្រឹមតែឈរ នោះត្រូវប្រើរបៀបតែមួយ ខ្វះតែអង្គុយប៉ុណ្ណោះ ។

១)– របៀបថ្វាយបង្គំ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងក្នុងព្រះរាជពិធីទ្វាទសមាស ដែលទ្រង់ប្រោសព្រះរាជទាននាហ្មឺនសព្វមុខមន្ត្រីធំតូចគ្រប់ដំណែង ចូលក្រាបបង្គំគាល់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យហើយព្រះរាជទានកៅអីឲ្យអង្គុយគាល់ ។

www.budinst.gov.kh www.elibraryofcambodia.org

របៀបនេះរៀបឡើងតាមសម័យអារ្យធម៌អឺរ៉ុប ក្នុងនាចុងរាជ្យព្រះបាទសម្តេចព្រះស៊ីសុវត្ថិចមចក្រពង្ស ព្រះចៅព្រះរាជាណាចក្រកម្ពុជាធិបតី តែពុំបានផ្លាស់បោលទាំងអស់ទេ គ្រាន់តែប្តូរអង្គុយពីបមីងកៅអីប៉ុណ្ណោះ ។

គ)– របៀបថ្វាយបង្គំដែលអង្គុយកៅអី គឺក្រោកឈរទើបផ្តើមសំយុងដៃទាំងពីរឲ្យត្រង់ចុះ ។ រួចលើកឡើងប្រណម្យនៅដើមទ្រូង ឱនក្បាលចុះ លើកដៃទាំងពីរទទួលក្បាលនៅត្រង់ប្រជុំចិញ្ចើម ទំលាក់ដៃទាំងពីរប្រណម្យមកត្រឹមដើមទ្រូង ទាំងងើបក្បាលឡើងឲ្យត្រង់ឲ្យស្មើគ្នា រួចទើបសំយុងដៃទាំងពីរចុះតាមដងខ្លួនដូចដើមវិញ ។

របៀបនេះ បើត្រូវថ្វាយបង្គំ ៣ ដងតាមព្រះរាជពិធីធំតូច ក៏ត្រូវធ្វើដដែលទៀត ឲ្យគ្រប់ ៣ ដងទើបអង្គុយចុះ ។

ក្នុងព្រះរាជពិធីធំៗក្នុងព្រះវាំងទាំងទេវាវិនិច្ឆ័យ មានភ្នាក់ងារម្នាក់ មុខក្រសួងខាងក្រុមព្រះរាជមន្ទីរ រាយគងជាសំគាល់សំរាប់ឲ្យមន្ត្រីធំតូចថ្វាយបង្គំ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឲ្យល្បបរៀបរយព្រមគ្នា ។

ឃ)- របៀបថ្វាយបង្គំក្សត្រិយ៍

ចំព្រះអង្គម្ចាស់ និងអ្នកអង្គម្ចាស់

បើអង្គុយពាប ត្រូវយកដៃទាំងពីរមកផ្គុំនៅដើមទ្រូងបន្ទន់ខ្លួនឱនក្បាលបន្តិចទៅមុខ ឲ្យចុងដៃជួបនឹងចុងច្រមុះរួចងើបឡើងឲ្យត្រង់ខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ដាក់ដៃទាំងពីរទៅលើភ្លៅ ដាក់ក្បាលឲ្យឱនបន្តិច កុំងើបខ្លាំងឲ្យហួសប្រមាណទាល់តែខូចឫកពាយើងដែលរៀបចំខ្លួនគោរព ។

*

* *

## សំពះ

សំពះគឺលើកដៃទាំងពីរផ្គុំឡើងឆ្ពោះត្រង់ទៅរកបុគ្គលណាមួយឬទៅរកវត្ថុអ្វីមួយដែលគួរគោរព ។

ពាក្យ " សំពះ " ប្រើច្រើនបែបដូចគេនិយាយថា ៖ សំពះការ គេយកកូនស្រីនិងកូនប្រុសឲ្យមកក្រាបសំពះផ្ទឹមគ្នា ក្នុងវេលាដែលរៀបអាពាហ៍ពិពាហ៍ ឲ្យជាភរិយាស្វាមី ។

" សំពះគ្រូ " គឺសំពះគោរពចំពោះគ្រូ ឬចំពោះគុណ ។

" សំពះសុំទោស " គឺសំពះអង្វរសុំឲ្យអត់ទោសឲ្យ ។

ក្នុងទីនេះ ត្រូវអធិប្បាយឲ្យក្បោះក្បាយបន្តិចអំពី " សំពះសួរ " និង " សំពះលា " ។

*

* *

## សំពះសួរ និង សំពះលា

គឺសំពះបុគ្គលណាមួយដែលគួរគោរព ហើយបញ្ចេញពាក្យថា សួរសុខទុក្ខផងជាការគួរសម ។

www.budinst.gov.kh www.elibraryofcambodia.org

ដំណើរ "សំពះ" នេះ ត្រូវក្មេងសំពះចាស់មុន គឺត្រូវកូនសំពះមាតា-បិតា, ចៅសំពះជីដូន-ជីតា, ក្មួយសំពះមីងមា, ប្អូនសំពះបង, សិស្សសំពះគ្រូអាចារ្យ (គ្រូហស្ថ) អ្នកតូចសំពះអ្នកធំ, រាស្ត្រសំពះមន្ត្រី ... ។ល។ ត្រង់បុព្វការីគឺ ឪពុក-ម្ដាយ, ជីដូន-ជីតា, កុំគប្បីសំពះតបទៅកូនចៅវិញឡើយ ទុកជាមានបុណ្យសក្តិធំយ៉ាងណាក៏ដោយ ។

*

* *

## លក្ខណៈសំពះ

១.– កូនស្រី-ប្រុស សំពះមាតា-បិតា

ចៅ សំពះជីដូន-ជីតា

សិស្ស សំពះគ្រូអាចារ្យ

គប្បីលើកដៃប្រណម្យដាក់ដល់ប្រជុំចិញ្ចើម ។

២.– ខ្ញុំរាជការ-ភ្នាក់ងារគ្រប់ដំណែង សំពះចៅហ្វាយនាយ គប្បីលើកដៃប្រណម្យដាក់ត្រឹមមាត់ ។

៣.– មនុស្សស្មើសក្តិគ្នាជាមន្ត្រីដូចគ្នា ឬរាស្ត្រសាមញ្ញដូចគ្នា គប្បីលើកដៃសំពះគ្នាទៅវិញទៅមកត្រឹមដើមទ្រូង ។

www.budinst.gov.kh www.elibraryofcambodia.org

៤.– ក្រស្តសាមញ្ញ សំពះមន្ត្រីធំ ដូចជារដ្ឋមន្ត្រី ចៅហ្វាយខេត្ត ចាងហ្វាងសាលាតុលាការ ... ។ល។ (គឺមន្ត្រីដែលមានយសសក្តិ ជាទីឧកញ៉ា អ្នកឧកញ៉ា ...) គប្បីលើកដៃដាក់ដល់ច្រមុះ ។

សក្តិតូចចុះមក សំពះដាក់ដៃត្រឹមមាត់ក៏ល្មមហើយ ។

*

* *

## កិរិយាដែលសំពះ

កិរិយាដែលត្រូវរៀបចំខ្លួនសំពះ ត្រូវផ្គុំដៃទាំងពីរឲ្យចំពីមុខទៅដើមទ្រូង បើនឹងលើកឡើងទៅលើក្តី ទាញចុះមកក្រោមវិញក្តី ត្រូវឲ្យនៅត្រង់ពីមុខដកប កុំយកទៅដាក់ចំហៀងម្ខាងស្តាំឬខាងឆ្វេងឬមួយយកទៅលើលើស្មា ពុំនោះសោតរុញឲ្យឃ្លាតឆ្ងាយពីខ្លួនទៅមុខទៅក្រោយដូចជាហុចអ្វីឲ្យទៅអ្នកដែលយើងត្រូវគោរពនោះ ។

កិរិយាសំពះនេះ តែកាលណាលើកដៃឡើងហើយត្រូវឱនក្បាល-បន្តិចទើបសមរម្យ ។

សំពះជាទម្លាប់ទំនៀមខ្មែរ ប្រើសំរាប់គោរពគ្នាទៅវិញទៅមកក្នុងការកិច្ចសួរសុខទុក្ខគ្នា “សំពះសួរនឹងសំពះលា” ជាធម្មតារបស់ជាតិយើង ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## × គំនាប់ងក់ក្បាលចាប់ដៃ

ការកិច្ចដែលគេត្រូវគំនាប់គ្នាដោយកិរិយាងក់ក្បាលនឹងចាប់ដៃគ្នានេះ ជារបៀបគួរសមគោរពគ្នារបស់ជនប្រទេសអឺរ៉ុបជាដំបូង ៗ សព្វថ្ងៃរបៀបនេះសាយភាយពេញលោកទាំងមូលទៅហើយ ៗ តែនៅចំណែកប្រទេសអាស៊ី ប្រទេសខ្លះធ្លាប់តែសំពះគ្នា គេនិយមប្រើកិច្ចការនេះ ទាំងពីរបែបគឺ សំពះផង ចាប់ដៃគ្នាផង ៗ

លក្ខណៈសំពះបានអធិប្បាយរួចមកហើយ ឥឡូវនេះនឹងអធិប្បាយអំពីគំនាប់ចាប់ដៃគ្នាតទៅទៀត ៗ

កិរិយាគំនាប់ចាប់ដៃគ្នានោះ មានលក្ខណៈជាសំខាន់ណាស់ គឺ គេគំនាប់គោរពគ្នាដោយចាប់ដៃស្តាំនឹងដៃស្តាំ ព្រោះគំនាប់ចាប់ដៃនេះ ដែលកើតឡើងដំបូងនៅបស្ចិមប្រទេស គេចាប់ដៃគ្នាវេលាណាគេជួបគ្នា ដែលគេស្រឡាញ់គ្នាទុកចិត្តស្និទ្ធស្នាលស្នេហានឹងគ្នា ហើយគេសួរសុខទុក្ខគ្នាទៅវិញទៅមក តែគេមិនចាប់យូរពេកទេ គេចាប់តែ ១ ភ្លែតព្រមទាំងសួរគ្នាថា "សុខជាទេ" ហើយលែងទៅវិញ ៗ បើមានការត្រូវនិយាយច្រើន គេចេះតែនិយាយទៅមិនចាំបាច់ទុកដៃទាំងពីរឲ្យនៅជាប់គ្នាឡើយ ៗ នៅក្នុងឱកាសប្រជុំគ្នាក្តី បុណ្យអ្វីក្នុង ១ ថ្ងៃក្តី បើបានជួបគ្នាម្តងហើយ គំនាប់ចាប់ដៃគ្នាហើយ ៗ បែកគ្នាទៅទីដទៃ ៗ រៀងខ្លួនទៅ គ្រាដែលមកជួបគ្នាម្តងទៀតមិនបាច់ចាប់ដៃគោរពគ្នាទៀតទេ លុះត្រាតែ

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ត្រូវលាគ្នាទៅទីលំនៅរៀងខ្លួនទើបត្រូវចាប់ដៃម្តងទៀត ជាកិច្ចគំនាប់គោរពលាគ្នា ។

គេចាប់ដៃគំនាប់តែគេស្គាល់គ្នា បើពុំនោះសោតមានអ្នកណាមួយនៅក្នុងទីប្រជុំនាំអ្នកមិនស្គាល់ឲ្យស្គាល់គ្នាឡើង ដោយបង្ហាញមុខនឹងប្រាប់នាម, ត្រកូល, របរកស៊ី ឬ សក្តិយសថា "នេះលោក... ធ្វើការជា..." យ៉ាងនេះឡើងជាដំបូង ទើបជនដែលមិនស្គាល់គ្នានោះទទួលស្គាល់គ្នាភ្លាមដោយរីករាយ ហើយហុចដៃស្តាំចាប់គោរពគ្នាទៅវិញទៅមក ។

កិរិយាដែលនឹងចាប់ដៃគ្នានោះ ក្មេង(១) មិនត្រូវហុចដៃទៅចាស់មុនទេ រាស្ត្រមិនត្រូវហុចដៃទៅក្សត្រិយ៍មុនទេ សាមញ្ញជនមិនត្រូវហុចដៃទៅមន្ត្រីមុនទេ ប្រុសមិនត្រូវហុចដៃទៅស្រីមុនទេ ។

បើជួបប្រទះប៉ះមុខហើយ ក្មេងក្តី រាស្ត្រក្តី ជនសាមញ្ញក្តី ប្រុសក្តី ត្រូវតែឈរទឹមជើងហើយឱនក្បាល បន្ទន់ខ្លួនឱនទៅមុខបន្តិចគោរពសិន ចាំឲ្យចាស់ឬក្សត្រិយ៍ មន្ត្រី ស្រីនោះៗ ហុចដៃមកសិនសឹមទទួលទៅវិញ ទើបជាការគោរពគួរសមរៀបរយល្អ ។

តែយើងទាំងអស់គ្នា មិនត្រូវដើរទៅកេះគ្នាហើយចាប់ដៃគ្នាទេ បើចង់គោរពគ្នា ត្រូវដើរទៅឲ្យចំពីមុខឈរឱនក្បាលឲ្យឃើញគ្នាសិន សឹមគំនាប់ចាប់ដៃគ្នា ។

---

(១) ក្មេងគឺមានអាយុតិចជាង ។

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY



កិរិយាដែលនឹងចាប់ដៃគ្នានោះ មិនត្រូវច្របាច់ឲ្យឈឺទេ ត្រូវចាប់ដោយទន់ភ្លន់ ត្រូវចាប់ឲ្យពេញដៃទៅវិញទៅមក ព្រោះបើម្នាក់ចាប់តែត្រឹមចុងដៃ ទុកជាមានចិត្តមិនស្មោះនឹងអ្នកមួយនោះ ។ ចាប់ហើយត្រូវលែងឲ្យស្រួលទៅវិញ កុំរលាស់ ឬ កញ្ឆក់ទាញចេញមក ។

អ្នកណាមួយដែលយើងមិនស្គាល់តែគេស្គាល់អ្នកដែលនៅជិតយើង គេគំនាប់គោរពចាប់ដៃអ្នកនោះ គេគិតថា ត្រូវការគួរសមនឹងយើងផង នោះបើគេគោរពយើង ដោយឱនក្បាលយើងក៏ត្រូវឱនតបទៅវិញ បើគេញញឹមមកក៏ត្រូវញញឹមតបទៅវិញ បើគេហុចដៃមកយើង ៗ គប្បីតែហុចដៃទៅចាប់វិញ ។ កុំហុចដៃឆ្វេងទៅគេ លើកតែដៃស្តាំយើងឈឺ ឬកំរើកមិនរួច ។

កាលណាគេរលឹកនឹកគ្នាណាស់ គេចាប់ដៃគ្នាសួរសុខ-ទុក្ខ មិនហួសពី ២ ឬ ៣ វិនាទីទេ ។

គេចាប់ដៃគ្នា គេមិនលើកកែងដៃឲ្យស្មើនឹងស្មា ឬ ចុងដៃឲ្យខ្ពស់ឡើងកំពស់ចុងច្រមុះទេ ។ ត្រូវតែទំលាក់ដៃសំយុងឲ្យល្មមសមគួរ ។

X កាលកំពុងចាប់ដៃគ្នា ត្រូវមើលមុខគ្នាឲ្យត្រង់ទៅត្រង់មក ដើម្បីសំដែងទឹកចិត្តមេត្រីស្មោះ ។

បើដៃយើងពុំស្អាត មានប្រឡាក់ដោយវត្ថុស្មោកគ្រោកមិនគប្បីនឹងហុចទៅទទួលចាប់លោកអ្នកដែលហុចដៃមក នោះត្រូវបញ្ហាញដៃយើង

www.budinst.gov.kh www.elibraryofcambodia.org

ហើយសូមទោសថា ដៃខ្ញុំពុំស្អាត យ៉ាងនេះទើបគួរសម ។ មិនត្រូវគិតខ្លាចថា ឥឡូវលោកអ្នកធំហុចដៃមកហើយ យើងត្រូវតែទទួលកុំខានឡើយ ថ្វីបើដៃក្រខ្វក់ យ៉ាងនេះត្រឡប់ជាអំពើមិនគោរពទៅវិញ ។

*

* *

## ប្រគេន - ថ្វាយ - ជូន

ពាក្យថា “ប្រគេន, ថ្វាយ, ជូន” ទាំង ៣ ម៉ាត់នេះមានន័យដូចគ្នា តែមានកិរិយាផ្សេងគ្នា គឺបានសេចក្ដីថា “ឲ្យ” ។ គឺ “ឲ្យ” ដោយវាចា និងឲ្យដោយកាយ ។

វត្ថុឯណាដែលលើកមិនរួច ត្រូវប្រើតែវាចាថាប្រគេន, ថ្វាយ, ជូន ទុកជាស្រេចបរិបូណ៌ ។

នឹងអធិប្បាយពីកិរិយាលើកប្រគល់ឲ្យដល់ដៃ ។

“ប្រគេន” និយាយអំពីកិរិយាលើកវត្ថុផ្សេងៗប្រគេនដល់ព្រះហស្ត ព្រះភិក្ខុសង្ឃឲ្យត្រឹមត្រូវដល់ហត្ថបាស ។

“ថ្វាយ” ( ពាក្យរាជសព្ទ ) និយាយត្រង់លើកវត្ថុផ្សេងៗ ថ្វាយដល់ក្សត្រិយ៍ ។

“ជូន” ប្រើត្រង់លើកវត្ថុផ្សេងៗ ជូនដល់ដៃបុព្វការី, គ្រូអាចារ្យ, មន្ត្រី, ចាស់ព្រឹទ្ធាចារ្យ ឬ បុគ្គលណាមួយ ដែលយើងត្រូវគោរព ។

www.budinst.gov.kh www.elibraryofcambodia.org

កិរិយា ប្រគេនក្តី, ថ្វាយក្តី, ជូនក្តី, ត្រូវកាន់របស់ដែលនឹងលើកប្រគេនថ្វាយជូនទៅនោះ ដោយដៃទាំងពីរទើបពេញលក្ខណៈ នៃគារវកិច្ច ។ ចុះបើកាន់តែដៃ ១ វិញ នោះមិនគួរ គេឲ្យឈ្មោះថា "ហុច" ទៅវិញ ។

* * *

## ហុច

"ហុច" គឺឲ្យដោយដៃតែម្ខាងប្រយោល ។ ដូច្នេះ កិរិយាដែល "ប្រគេនក្តី, ថ្វាយក្តី, ជូនក្តី" មិនត្រូវហុចឲ្យសោះ ។ តែប្រសិនបើយើងមានវត្ថុអ្វីមួយ ត្រូវប្រើដៃស្តាំកាន់ឲ្យជាប់ នឹងដាក់ចោលមិនបាន ឬ នឹងលែងឲ្យរបូតពីដៃមិនបាន គប្បីប្រើកាន់វត្ថុនោះនឹងដៃឆ្វេងហើយកាន់របស់ដែលត្រូវហុចនោះនឹងដៃស្តាំ ទើបកប់បញ្ចូលទៅក្នុងការគោរពបានដែរ ដោយសន្តោសអធ្យាស្រ័យថាដៃឆ្វេងជាប់រវល់ ដៃស្តាំកប់យកជាទីគោរពបាន ។ យើង "ហុច" បានតែអ្នកមានយសសក្តិស្មើគ្នា ឬមួយអ្នកធំ ហុចឲ្យអ្នកតូច ។

កាន់របស់ដែលមានដង, មានផ្លែមុត, មានចុងស្រួច, កាន់ក្បើង... ។ល។

www.budinst.gov.kh www.elibraryofcambodia.org

ពោះមិនប្រគេន, ថ្វាយ, ជូន; ហុច របស់ដែលមានដង, មានផ្លែមុត, មានចុងស្រួច, ត្រូវកាន់បង្វិលដងទៅខាងអ្នកទទួល មុខដែលមុត, ស្រួចមកខាងយើង ។

ប្រៀបដូចកាំបិត, ដងប៉ាកកា, អំបោស ... ។ល។ នោះត្រូវបង្វិលមុខកាំបិត, ចុងស្វាបប៉ាកកា, ចុងអំបោស, មកខាងយើងដែលជាអ្នកប្រគេន, អ្នកថ្វាយ, អ្នកជូន, អ្នកហុច ។ បើជាកន្ទុយ[illegible]សដែលមានភ្លើង ឬជាកន្ទុយបារីដែលកំពុងឆេះនោះ ក៏ត្រូវបង្វិលខាងភ្លើងមកខាងខ្លួនយើងសិនសឹមប្រគេន, ថ្វាយ, ជូន, ហុច ខាងដែលឥតភ្លើងនោះទៅ ។

*

* *

## របស់ដែលនឹងយកទៅប្រគេនលោកសង្ឃ ថ្វាយក្សត្រិយ៍ ជូនបុព្វការី ឬចៅហ្វាយនាយ ឬចាស់ព្រឹទ្ធាចារ្យ ។

របស់ឯណាដែលយើងចាត់ចែង នឹងយកទៅនោះ គប្បីរកភាជន៍ដ៏សមល្មមបកផ្កល់ ១ ជាន់ទៀតទើបគួរ ។

ប្រៀបដូចយើងចង់យកម្ហូបចំណីទៅប្រគេនព្រះសង្ឃ ។ ម្ហូបចំណីទាំងនោះដាក់ក្នុងភាជនៈកែវឬចានរួចទៅហើយ តែត្រូវឲ្យមានជើងពាន

www.budinst.gov.kh www.elibraryofcambodia.org

ឬថាស ១ ទ្រកាផន: ដែលដាក់ម្ហូបចំណីនោះទៀតទើបគ្រប់បរិបូណ៌ក្នុងការគោរព ។

ទោះជាថ្វាយក្សត្រិយ៍ក្តី ជូនមាតាបិតាគ្រូអាចារ្យក្តី... ។ល។ គប្បីតែរៀបចំឲ្យប្រសើរ ដូចយ៉ាងអធិប្បាយមកនេះ ។

ដូចផ្កាយដែលនាំយកទៅថ្វាយក្សត្រិយ៍ខត្តិយត្រកូល អ្នកមានទ្រព្យគេច្រើនប្រើដំកល់លើថាសមាសប្រាក់ដើម្បីនឹងលើកដំកៀងនៃផ្កាយនោះ ៗ ចំពោះរូបមួយ ។

បើជាចំពោះច្រើនរូបវិញនោះត្រូវប្រើរបៀបដែលនិយាយហើយ តែនៅក្នុងការគោរពជាដកប ។

ឧបមាដូចប្រគេនទឹកតែព្រះសង្ឃច្រើនអង្គ ឬ ជូនទឹកក្រូចឧបាសកច្រើននាក់ ៗ ទឹកតែដាក់ក្នុងពែងតែ ពែងនេះគ្មានបានទ្រ ទឹកក្រូចដាក់ក្នុងកែវ កែវនោះគ្មានបានទ្រ តែត្រូវដម្កល់ពែងតែនឹងកែវទឹកក្រូចដាក់លើថាស ១ ធំ ចំនួនច្រើនពែង ច្រើនកែវ ។

យើងលើកទៅតាំងថាស កិច្ចដែលនឹងប្រគេនលោក ត្រូវចូលទៅជិតហើយនិមន្តលោកឲ្យចាប់យក ១ អង្គ ១ ពែង ឬ ២ ពែងតាមគួរ យ៉ាងនេះទើបត្រូវតាមក្បួនរេទាម័យ (បើជូនភ្ញៀវក៏ដូចគ្នា) ។

សូមកុំភ្លេច.– យើងមិនត្រូវចាប់ពែងតែ ឬ កែវទឹកប្រគេន ថ្វាយ-ជូន ទៅឲ្យសោះឡើយ ដើម្បីកុំឲ្យមានរង្កៀសចិត្តថា ដៃយើងតើស្អាតឬមិនស្អាត ។

www.budinst.gov.kh www.elibraryofcambodia.org

មានកាលលោកអ្នកត្រូវការកេសដ្ឋៈ ដោយប្រញាប់ប្រញាល់ពេក យើងលើកជូន ១ កែវទៅ តែមិនត្រូវកាន់មាត់កែវនោះឲ្យសោះ ឬ ច្រមពីលើ ត្រូវទ្រកែវនោះឲ្យនៅលើបាតដៃ ឬ ក៏ចាប់កាន់ខាងបាតកែវ ទើបរួចពីសេចក្ដីសង្ស័យ នឹងដៃស្អាត ឬ មិនស្អាត ។

នៅឯកាសប្រជុំមួយ ៗ ហើយមានវរជនជាអធិបតី ដូចជាសម្ដេចព្រះសង្ឃនាយក ឬ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ល។ បើយើងប្រគេន ឬ ថ្វាយកេសដ្ឋៈ ត្រូវដំកល់ក្តែនោះឲ្យសមរម្យ ឲ្យដាច់ឡែកអំពីកៀវសាមញ្ញមិនត្រូវធ្វើឲ្យខុសទើបគួរ ។

*

* *

## និយាយ

និយាយជាកិរិយាដែលបញ្ចេញសំដី ពោលពាក្យល្អ ពីរោះផ្អែមពីសា ឬ អាក្រក់ ទ្រគោះបោកបោះ ខ្លាំងតិចឡើបខ្សៀវ... ។ល។

កិរិយាដែលនឹងនិយាយស្ដី មានច្រើនលក្ខណៈណាស់ ដូច្នេះ បើយើងនឹងនិយាយស្ដីត្រូវគិតឲ្យស្រេចសឹមនិយាយ ។ បុរាណលោកចងជាពាក្យប្រដៅទុកមកថា "សំដីជាឯក លេខជាទោ" ។

នេះបានសេចក្ដីថា ពាក្យសំដីដែលចេញពីមាត់ទៅហើយ អាចនឹងនាំឲ្យមានផលប្រយោជន៍ក៏មាន មានកាលបើនិយាយទៅហើយពានទៅលើខុសនុ៎ះ នឹងឲ្យខូចផលប្រយោជន៍ក៏មាន ។ យ៉ាងនេះហើយ ទើប

www.budinst.gov.kh www.elibraryofcambodia.org

លោកកប់ថា "សំដីជាឯក" ។ "ឯលេខជាទោ" នោះមានន័យថា ការសរសេរឬគិតបូកបោះជាការបន្ទាប់បន្សំទេ ព្រោះការសរសេរជាសេចក្ដីគេព្រាងសិន គេអាចនឹងកែសេចក្ដីព្រាងនោះម្ដង ឬ ពីរបីដងទៀតក៏បាន បើត្រឡប់ជាខុសខូចទៅវិញក៏លុបអស់ចិត្ត ដោយការគិតបិនដល់ ។ ឯពាក្យសំដីនិយាយ តែផ្ដុលផ្លួសខុសទៅហើយ ពិបាកនឹងកែណាស់ ។ សមនឹងពាក្យចាស់ថា "រនាបបាក់យករនាបជួស តែសំដីហួសគ្មានអ្វីជួសបាន" ។ មិនតែប៉ុណ្ណោះទេ លោកពោល ១ ម៉ាត់ទៀតថា "មនុស្សគេយកសំដី ដំរីគេយកភ្លុក" នេះមានន័យថា សំដីមនុស្សនេះតែនិយាយចេញពីមាត់ទៅហើយ គង់អ្នកដទៃឮស្ដាប់បាន ថានិយាយល្អឬអាក្រក់ មិនដែលសំដីនោះលិបចូលបាត់ទៅក្នុងមាត់វិញទេ ប្រៀបដូចជាភ្លុកដំរី ដែលដុះចេញពីមាត់វាមកហើយ មិនដែលលិបចូលទៅក្នុងមាត់វាបានវិញទេ ។

បានជាលោកទុកសំដីនេះ ដូចភ្លុកដំរី ។

លោកប្រៀប ១ ម៉ាត់ទៀតថា "អណ្ដាតជាកង់កន្ទង សុខ-ទុក្ខ ទោសផង កើតពីអណ្ដាត" ។

បានសេចក្ដីថា ពាក្យសំដីដែលចេញពីមាត់ រមែងឲ្យសុខនឹងទុក្ខទោសដល់អ្នកនិយាយ ។ ហេតុនេះហើយ លោកប្រដៅថា ត្រូវគិតឲ្យវែងទៃទមុននឹងនិយាយ ត្រូវនិយាយឲ្យត្រឹមត្រូវ ត្រូវនិយាយដោយ

www.budinst.gov.kh www.elibraryofcambodia.org

សុភាព និយាយដោយបញ្ញាពិចារណាឲ្យឃើញពិតឃើញមែន ដល់ត្រចៀកអ្នកស្តាប់ ។

*

* *

# របៀបនិយាយ

និយាយមានច្រើនបែបផែន មានជាច្បាប់ក្បួនដែលបុរាណបណ្ឌិតលោកចងទុកមក ។ របៀបនិយាយនឹងរបៀបសរសេរ ពុំបានជាប្លែកគ្នាប៉ុន្មានទេ ។ ខុសគ្នាបន្តិចបន្តួចដោយសារតែរបៀបនិយាយច្រើនប្រើដំណើរកាត់ប្រួតឲ្យខ្លី ៗ ប៉ុណ្ណោះ ។

១.– និយាយនឹងព្រះសង្ឃ ជារបៀប ១ ដោយឡែក ដែលយើងពល់គ្នាចេះចាំហើយ ។

២.– និយាយនឹងក្សត្រិយ៍ខត្តិយត្រកូល នេះត្រូវរៀនតាមក្បួនរាជសព្ទ ព្រោះក្សត្រិយ៍មានច្រើនថ្នាក់ ហើយមានរបៀបនិយាយតាមឋានន្តរសក្តិ ។

និយាយនឹងព្រះមហាក្សត្រិយ៍ទ្រង់រាជ្យ ១

– ក្សត្រិយ៍ជាន់ខ្ពស់ គឺស្តេចតាំងក្រុម ១

– ក្សត្រិយ៍ ទីព្រះអង្គម្ចាស់ ១

www.budinst.gov.kh www.elibraryofcambodia.org

និយាយនឹងក្សត្រិយ៍វង្សគអន្តចាស់ ១

វង្សគអន្ត ១

ត្រង់នេះ យើងត្រូវឲ្យចេះឲ្យស្ទាត់នូវពាក្យដែលមានក្នុង «ក្បួនរាជសព្ទ» ។ បើឯការសរសេរវិញត្រូវអាស្រ័យក្បួន «ប្រជុំលិខិត» ជាគំរូ ។

៣.- និយាយនឹងមន្ត្រីធំ-តូចដែលលោកមានយសសក្តិជារាជ-អាមាត្យគឺជារដ្ឋមន្ត្រី ឧត្តមមន្ត្រី វរមន្ត្រី អនុមន្ត្រី ... ។ ពាន់ហ្មឺននឹងទៅក្រម ... ។ល។ ប៉ុណ្ណោះជាដើម នោះយើងគប្បីរៀនតាមទំរង់សក្តិ ដែលរៀបចំជារបៀបសរសេរក្នុងក្បួន «ប្រជុំលិខិត» ។

សូមរំលឹកថា ការនិយាយនេះមិនត្រូវឲ្យស៊ុនខ្ពស់ពេក ហួសប្រមាណឡើយ ។ ត្រូវគិតថ្នាក់របស់ខ្លួនសិនសឹមគិតដល់យសសក្តិលោកណាដែលយើងនិយាយផង ។

ទីនេះធ្វើឧទាហរណ៍បន្តិច. ដើម្បីកំណត់របៀបនិយាយគោរពចំពោះមន្ត្រី ។ ដូចជាពាក្យថា «បាទ, ខ្ញុំបាទ, ខ្ញុំប្របាទ, ខ្ញុំប្របាទម្ចាស់ ។

នេះត្រូវចាំថា ៖

ស្មើសក្តិគ្នា ត្រូវឆ្លើយ បាទ

តូចជាង ១ ទៅ ២ សក្តិ — ខ្ញុំបាទ

តូចជាង ៣ សក្តិ — ខ្ញុំប្របាទ

www.budinst.gov.kh www.elibraryofcambodia.org

តួបតី ៤ ដល់ ៧ សក្តិ ត្រូវឆ្លើយ ខ្ញុំប្របាទម្ចាស់

កស្ត្រីឆ្លើយរដ្ឋមន្ត្រី ខ្ញុំប្របាទម្ចាស់ជាដរាប ។

ចំណែកស្រី ៗ វិញ បណ្តាភរិយាមន្ត្រីមានឋានន្តរសក្តិហៅថា ៖

១.– ជំទាវ

២ – លោកស្រី

៣.– អ្នកស្រី

## ជំទាវ

ដែលទើបហៅបានថា "ជំទាវ" លុះត្រាតែភរិយាពេញច្បាប់នៃរដ្ឋមន្ត្រី ( សេនាបតី ) ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសតាំងដោយព្រះរាជប្រកាសឬព្រះរាជក្រឹត្យ ។ បើពុំដូច្នោះទេ បណ្តាភរិយាមន្ត្រីជាន់ខ្ពស់ ស្វាមីមានយស ១០, ៩, ៨, ៧ ហ៊ូពាន់ ត្រូវហៅបានត្រឹមលោកស្រី ព្រោះស្វាមីទីជាឧកញ៉ា តែត្រូវចែកជាពួក ៗ តទៅទៀត ។

## លោកស្រី

១.– ស្វាមីមានសក្តិ ១០ ហ៊ូពាន់ ទីលោកអ្នកឧកញ៉ា ភរិយាត្រូវជា "លោកស្រី" ជាន់ឯក ( ដើមខ្សែ )

២.– ស្វាមីមានសក្តិ ៩ ហ៊ូពាន់ ទីអ្នកឧកញ៉ា ភរិយាត្រូវជា "លោកស្រី" ជាន់ទោ ( បន្ទាប់ )

www.budinst.gov.kh www.elibraryofcambodia.org

៣.- ស្វាមីមានសក្តិ ៨ ហូតាន់ ទីឯកញ៉ា គរិយាត្រូវជា "លោកស្រី" ជាន់ត្រី (ទី៣)

៤.- ស្វាមីមានសក្តិ ៧ ហូតាន់ ទីឯកញ៉ាដែរ គរិយាត្រូវជា "លោកស្រី" ជាន់ចត្វា (ទី៤)

## អ្នកស្រី

១.- ស្វាមីមានសក្តិ ៦ ហូតាន់ទី "ព្រះ" គរិយាត្រូវហៅថា "អ្នកស្រី" ជាន់ឯក (ដើមខ្សែ)

២.- ស្វាមីមានសក្តិ ៥ ហូតាន់ទី "ហ្លួង" គរិយាត្រូវហៅថា "អ្នកស្រី ជាន់ទោ (បន្ទាប់)

៣.- ស្វាមីមានសក្តិ ៤ ហូតាន់ទី "ឃុន" គរិយាត្រូវហៅថា "អ្នកស្រី" ជាន់ត្រី (ទី ៣)

៤.- ស្វាមីមានសក្តិ ៣ ហូតាន់ ទី "ម៉ឺន" គរិយាត្រូវហៅថា "អ្នកស្រី" ជាន់ចត្វា (ទី ៤)

ឯកស្ត្រីសាមញ្ញត្រូវហៅថា "អ្នក" គឺជាការល្មមសមគួរហើយ ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## ហៅជិត - ហៅចម

បណ្ដាស្ត្រីជាព្រះស្នំព្រះមហាក្សត្រិយ៍ ស្ដេចផែនដី ត្រូវបានយស ជាលំដាប់ ហៅថា ឃុន, ម៉ម, អ្នកម្នាង, អ្នកនាង, ដែលព្រះរាជាទ្រង់ ព្រះមេត្តាប្រោសលើកឡើងដោយព្រះរាជទានឲ្យ ព្រះរាជហត្ថលេខា ក្នុងសញ្ញាប័ត្រជាសំគាល់ នោះត្រូវគោរពពេញទីជាព្រះស្នំម្ចាស់ផែនដីៗ

ការនិយាយស្ដីមិនត្រូវហៅថា ជំទាវ, លោកស្រី, អ្នកស្រី, ឬអ្នកទេ ត្រូវហៅថា លោកឃុន, ម៉ម, អ្នកម្នាង, អ្នកនាង យ៉ាងនេះទើបត្រូវ ។

*

* *

## និយាយក្នុងទីប្រជុំ

និយាយក្នុងទីប្រជុំ ត្រូវប្រើពាក្យសំដីពីរោះផ្អែមពីសា ប្រើពាក្យ គោរពឲ្យត្រឹមត្រូវតាមទំរង់សក្តិ តាមថ្នាក់តាមជាន់ គួរសមនឹងគ្នាទៅ វិញទៅមកតាមសណ្ដាប់ប្រវេណី គឺជាឲ្យស្គាល់បព្វជិតនឹងគ្រហស្ថ,

ឲ្យស្គាល់ក្សត្រិយ៍ នឹង បព្វជិត,

ឲ្យស្គាល់ក្សត្រិយ៍ នឹង ប្រជារាស្ត្រ

ឲ្យស្គាល់ក្សត្រិយ៍ នឹង មន្ត្រីធំ-តូច

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យស្គាល់មន្ត្រី នឹង ប្រជារាស្ត្រ

ឲ្យស្គាល់ប្រជារាស្ត្រ នឹង ប្រជារាស្ត្រ

ឲ្យស្គាល់ចាស់ នឹង ក្មេង

ឲ្យស្គាល់ស្ត្រី នឹង បុរស

ឲ្យស្គាល់មាតា-បិតា នឹង កូន

ឲ្យស្គាល់ជីដូន-ជីតា នឹង ចៅ

ឲ្យស្គាល់ចៅហ្វាយនាយ នឹង អ្នកបំរើ

ឲ្យស្គាល់ឪពុកធំ ម៉ីង-មា នឹង ក្មួយ ។ល។

ដំណើរនិយាយគាន់គ្នាទៅវិញទៅមក ប្រកបបរិបូណ៌ដោយគារវកិច្ចគួរគង់ហារហើយ ការចរចានោះសោតពីរោះ រៀបរយល្អកល្អាយ សប្បាយទាំងអស់គ្នា ។

ករណាហើយ មិនចេះប្រកបពាក្យសំដីពីរោះល្អ ប្រើតែពាក្យថោកទាប ពាក្យទ្រគោះបោកបោះ ពាក្យអសុរស ពាក្យចាក់ដោត ហាក់ដូចជាថ្នាំពុល អ្នកនោះរមែងបណ្ដាលនូវសេចក្ដីក្ដៅក្រហាយ សេចក្ដីក្រោធខឹងនឹងសេចក្ដីជំលោះដល់អ្នកដែលបានឮបានស្ដាប់ ដោយទទួលនូវរសជាតិនៃពាក្យស្មែងនោះ ។

*

* *

# ទីប្រជុំមានច្រើនយ៉ាង

ក)- ប្រជុំស្តាប់ធម៌ទេសនា ឬ សូត្រមន្ត
ប្រជុំស្តាប់សុន្ទរកថា
ប្រជុំស្តាប់សន្និសីទ
ប្រជុំស្តាប់ច្រៀង
ប្រជុំមើលកុនស្រមោល

ប្រជុំទាំង ៥ នេះ មានតែ ១ នាក់និយាយ ឬ ពីរនាក់និយាយឆ្លើយឆ្លងគ្នា ដោះបញ្ហាផ្សេងៗ ។ ដូច្នេះ អ្នកដែលចូលទៅសន្និបាតប្រជុំនៅទីនោះៗ ត្រូវកាន់កិរិយាសុភាពរៀបរយដោយគោរពដល់អ្នកសំដែង គឺមិននិយាយឬខ្សឹបគ្នាឲ្យឮសំឡេង ១ ឡើងទៀត ឲ្យរំខានដល់អ្នកទាំងឡាយដែលគេប្រាថ្នានឹងស្តាប់យកជាការផង ។ មិនតែប៉ុណ្ណោះឡើយ លោកអ្នកសំដែង រមែងកើតបដិឃៈ ចង្អៀតចង្អល់ខ្វល់ចិត្ត ដ្បិតអ្នកស្តាប់សំដែងអាកប្បកិរិយាមិនពេញចិត្តនឹងស្តាប់ ដូច្នេះគប្បីតែនាំគ្នាដើរចេញពីទីនោះឲ្យផុតទៅ សឹមនិយាយគ្នាតាមអំពើចិត្តខ្លួន ទើបសមជាអ្នកស្គាល់កាលនឹងកិច្ចគេឯងរាល់គ្នា ។

របៀបចូលស្តាប់ធម៌ទេសនា ជាសេចក្តីបដិបត្តិ ១ ដ៏សំខាន់ក្រៃលែងសំរាប់អ្នកកាន់សាសនា ។ តែកាលណាគេចូលទៅក្នុងព្រះវិហារក្តី សាលាក្តី ពេន៍ធានក្តី ឬក្នុងគេហស្ថានឯណានីមួយក្តី ដែលគេនិមន្ត

ធម្មកថិកមកសំដែងធម៌ នោះយើងអ្នកស្តាប់មិនត្រូវនិយាយឲ្យព្រួអ៊ូអរសោះឡើយ មិនត្រូវយកកូនទៅទៅផង ហើយបណ្តែតបណ្តោយឲ្យប្រឡូកប្រឡែងគ្នាព្រួសូរសព្ទស្រែកទ្រហឹងអឹងកង ឲ្យរំខានដល់ចាស់ទុំដែលកំពុងប្រុងស្មារតីត្រងត្រាប់យកខ្លឹមសារនៃធម៌ទេសនានោះ ។ ។

១)– ប្រជុំរបស់សមាគម

ដំណើរប្រជុំរបស់សមាគមនីមួយ ៗ នោះតែងតែមានគណៈកម្មាធិ-ការនាយកជាធំ មានប្រធាន - អនុប្រធាន - អគ្គលេខាធិការ ... ។ល។ ជាអ្នកចាត់ការបើកឱកាសនិយាយពិគ្រោះពីការផ្សេង ៗ តាមរបៀបវារៈ ។

នេះបណ្តាសមាជិកដែលទៅប្រជុំផង មិនត្រូវដណ្តើមគ្នានិយាយជជែកស្រែកគំហកកំហែងគ្នាឯងទេ ឲ្យកើតជាជំលោះបានឡើយ ។ ត្រូវតែស្តាប់គ្នា ហើយនិយាយជជែកតក៏ តាមលំដាប់មុន ១ ម្នាក់ មិនត្រូវនិយាយកាត់គ្នាឲ្យខូចសេចក្តីអធិប្បាយរបស់អ្នក ១ ដែលកំពុងនិយាយបរិយាយពន្យល់ឲ្យឃើញហេតុឃើញផលឡើយ ។ ត្រង់នេះត្រូវដឹងថាមានតែប្រធាន ១ ទេ ដែលមានសិទ្ធិនឹងហាត់ហាមអ្នកនិយាយឲ្យឈប់បាន ដោយយល់ថា និយាយវែងពេកមិនបានការ ឬនិយាយគ្មានចុងគ្មានដើមចេញក្រៅរឿងដែលគេគោលទុកឲ្យនិយាយ ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

# និយាយលេង

ដំណើរនិយាយលេងជាល្បែងក្រមាច់សើចលេងនោះ ត្រូវកំផងពាក្យចំអេសចំអាស ៗ ត្រូវកំផងក្រែងមានស្រីញី ឬ ប្រុសឈ្មោលចូលមកជិតទីប្រជុំនោះ មិនសមនឹងឲ្យឮនូវពាក្យសំដីដែលយើងនិយាយគ្នាជាមិត្រស្និទ្ធ ៗ ពិតមែនតែយើងជាមិត្រនឹងគ្នា ចំណែកអ្នកដែលនៅជុំវិញយើង គេពុំរីករាយសប្បាយដោយពាក្យសំដីដែលជាអាស្រូវអប្រិយផល់ត្រចៀកគេឡើយ ម៉្លោះហើយ គេរមែងតែងតែតិះដៀលដល់យើងថាជាមនុស្សមិនស្គាល់ខុសត្រូវពោលពាក្យអាស្រូវនៅមុខគេ ៗ

ឯដំណើរនិយាយលេងសើចនេះ បានឥតទាស់តែនៅទីដទៃក្រៅពីគេហស្ថានដែលគេគ្មានទុក្ខ ៗ បើយើងទៅសួរគួរសមនឹងញាតិមិត្រដែលកំពុងមានទុក្ខដោយព្រាត់ប្រាសគ្នាស្លាប់រស់យ៉ាងណាក្តី មានជម្ងឺឈឺចាប់ជាទម្ងន់ក្តី មានធុរៈដោយលង់ទូកក្តី ដោយភ្លើងឆេះផ្ទះក្តី យើងគប្បីកុំនិយាយសើចលេងសប្បាយឲ្យសោះ ត្រូវសង្រួមកាយវាចាឲ្យស្រគត់ស្រគំឲ្យសមជាអ្នកជួយទទួលទុក្ខជាមួយនឹងក្រុមញាតិគេដែរ ៗ

បើប្រសិនណាជាយើងទៅហែសពតាមផ្លូវក្តី នៅទីប៉ាឆាក្តី យើងមានការនិយាយនឹងអ្នកណាមួយដោយខានពុំបាន ក៏ត្រូវនិយាយខ្សឹប ៗ កុំឲ្យឮលាន់ពាក្យសំដីឲ្យភ្ញាក់ផ្អើលដល់អ្នកដែលនៅផងគ្នាក្នុងទីនោះ ៗ នេះជាគារវកិច្ច ១ យ៉ាងសំខាន់ដែលយើងពលគ្នាគប្បីបំពេញឲ្យបរិបូណ៌

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះនៅពេលដែលយើងទៅបុណ្យខ្មោចនេះ យើងត្រូវតែមានធម៌សង្វេគរឭកឃើញដល់អាយុសង្ខារនៃយើងគ្រប់ៗគ្នា ។

*

* *

## និយាយខ្សឹប

ដំណើរនិយាយខ្សឹបនេះ គឺនិយាយតិចៗជិតត្រចៀកគ្នា ដើម្បីមិនឲ្យអ្នកដទៃដែលនៅជិតខាងឮផងបាន ។

និយាយខ្សឹបនេះ មានកាលត្រូវតែខ្សឹបទើបគួរ មានកាលខ្សឹបទៅជាហេតុអាក្រក់នាំឲ្យខូចការងារផ្សេងៗ ។ ដូច្នេះ យើងត្រូវឲ្យដឹងនូវកាលដែលទីងត្រូវខ្សឹបនឹងមិនត្រូវខ្សឹប ។

## ត្រូវនិយាយខ្សឹប

១.– នៅពេលដែលអ្នកនៅជិតខាងយើងនៅក្នុងបន្ទប់ជាមួយក្តី បន្ទប់ជាប់គ្នាក្តី នោះយើងត្រូវនិយាយខ្សឹប នៅពេលដែលគេដេកយប់ថ្ងៃ កុំឲ្យគេរំខានក្នុងដំណើរដែលគេសំរាកកំឡាំង ។

២.– យើងទៅសួរគួរសមនឹងញាតិមិត្ត ដែលមានជម្ងឺដំកាត់ ហើយត្រូវការតែស្ងាត់ គេចអំពីកន្ទ្រល់ផ្សេងៗ ត្រូវការតែសម្ងំផ្ទុំស្នាតើ

ឲ្យស្ងប់រម្ងាប់ប្រាសចាកការចង្អៀតចង្អល់ខ្វល់ចិត្ត ។ ដូច្នេះដើម្បីចៀសវាង សេចក្តីមិនគាប់ចិត្តអ្នកជម្ងឺ ដើម្បីជួយថ្នមចិត្តអ្នកជម្ងឺ នោះបណ្តាអ្នកទៅ សួរគួរសមដោយមេត្រី ត្រូវនិយាយស្តីឲ្យពីរោះ ហើយខ្លីៗផង ទើបគួរ ។ តែមានកាលខ្លះយើងអាចនឹងនិយាយលេងបន្តិចបន្តួចបាន នឹងអ្នកជម្ងឺដែលមានរោគស្រាល ជាការលួងលោមឲ្យបានអ្នកជម្ងឺនោះ សប្បាយរីករាយចិត្ត ជាប្រយោជន៍ឲ្យបានឆាប់ជាស្បើយស្លើយអំពីជម្ងឺ ដំកាត់នោះក៏សឹងមានដែរ ។

តែបើលោកគ្រូពេទ្យហាមមិនឲ្យអ្នកជម្ងឺនិយាយសោះ ខ្លាចក្រែង រោគកម្រើកខ្លាំងឡើង ដោយអ្នកជម្ងឺប្រឹងនិយាយ ដូច្នេះយើងត្រូវ ប្រតិបត្តិ គោរពតាមបំរាមពេទ្យ ។

៣.— ក្នុងក្បួនហែសព យើងត្រូវនិយាយខ្សឹបជាដរាប តាំងពីផ្ទះ រហូតដល់ទីបូជា ទាំងប្រើកិរិយាស្រគត់ស្រគំទៀតផង ។ បើប្រសិន ជាលោកអ្នកដែលប្រកបទូវសង្វេគធម៌ពិចារណាពីដំណើររបស់ជីវិតដែល ត្រាច់រង្គាត់ក្នុងវដ្តសង្សារ នោះប្រហែលជាលោកមិននិយាយសោះផង ព្រោះលោកជាប់ក្នុងព្រះកម្មដ្ឋានឯណាមួយក៏សឹងមាន ។

៚ ៚

www.budinst.gov.kh www.elibraryofcambodia.org

# មិនត្រូវនិយាយខ្សឹប

ក្នុងចំណោមប្រជុំគ្នាច្រើននៃសមាគមណាមួយ ដើម្បីពិគ្រោះដោះស្រាយបញ្ហាផ្សេង ៗ នោះបណ្ដាអស់លោកអ្នកជាសមាជិក គប្បីកុំប្រើកិរិយានិយាយខ្សឹបឲ្យសោះ ប្រយោជន៍ចៀសវាងនូវសេចក្ដីរង្កៀសសង្ស័យកើតមានឡើងរវាងគ្នាឯង ៗ តែសេចក្ដីរង្កៀសចិត្តកើតមានឡើងហើយកាលណា សេចក្ដីសាមគ្គីក្នុងសមាគមនោះរមែងរលាយបាត់បាក់បែកគ្នាមិនខាននាកាលនោះ ។

ការខ្សឹបដែលឲ្យកើតជាទោសដូចអធិប្បាយខាងលើនេះ យើងកុំគប្បីធ្វើឲ្យសោះ ។

មួយទៀត បើយើងមានការត្រូវខ្សឹបគ្នា តែដួនជាមានអ្នកឯណាមួយដើរមក នេះត្រូវរាំងកុំឲ្យគេសង្ស័យថាយើងខ្សឹបរិះគន់គេ ដូច្នេះគប្បីតែបង្អង់ខ្សឹប មួយស្របក់ ឲ្យអ្នកនោះដើរទៅហួសសិនជាការល្អ ជាការមិនឲ្យគេរង្កៀសចិត្តនឹងយើង ថាយើងនិយាយចុងដើមអំពីគេ ។

ដូចពាក្យ ១ ឃ្លាខាងក្រោមនេះថា

“ និយាយខ្សឹបឮឆ្ងាយ ដំណឹងតិចម្ងាយឮច្បាស់ ” ។

*

* *

www.budinst.gov.kh www.elibraryofcambodia.org

## មិនត្រូវនិយាយភាសាដទៃ

ក្នុងទីប្រជុំនីមួយ ៗ ដែលមានសុទ្ធតែជនជាតិជាមួយគ្នា ហើយគេពិភាក្សាជជែកពិគ្រោះគ្នាអំពីការផ្សេង ៗ ដោយប្រើភាសាជាតិរបស់ខ្លួន ព្រោះក្នុងទីប្រជុំនោះមានជនខ្លះមិនចេះភាសាដទៃក្រៅពីភាសាខ្លួន ៗ យើងរាល់គ្នាជាសមាជិក ឬ ជាទីប្រឹក្សាសមាគម ឬ សភានោះ ៗ កុំគប្បីប្រើភាសាដទៃនិយាយការអ្វីមួយផ្សេងនឹងសមាជិកផងគ្នា ២ – ៣ នាក់ ដោយឡែកទៅទៀត ។ ព្រោះដំណើរប្រើភាសាដទៃនៅចំពោះមុខជនជាតិដូចគ្នា ជាហេតុនាំឲ្យអ្នកទាំងពួងនៅទីនោះកើតរង្កៀសសៅហ្មងចិត្តគិតឡើងថាគេមានការមិនត្រង់ មានការលាក់កំបាំង មានការក្បត់គំនិត ... ។ល។ សេចក្ដីសង្ស័យយ៉ាងនេះកើតឡើងកាលណាហើយ សេចក្ដីសាមគ្គីនឹងបែកខូចនាកាលណោះ ។ ដូច្នេះហើយទើបលោកហាមថា កុំឲ្យនិយាយភាសាដទៃ នៅទីប្រជុំជនជាតិដូចគ្នា ដែលមានជនខ្លះមិនចេះភាសាដទៃ ដើម្បីរក្សាសេចក្ដីសាមគ្គីរបស់គ្នាឲ្យបានជាវៈ មាំទាំល្អតទៅ ។

តែបើនៅទីប្រជុំនោះ មានជនជាតិបរទេសមកផងដែរ ដូចនៅពេលលៀងអាហារ លៀងភេសជ្ជៈ ជូនដំណើរមិត្តភក្តិ ឡើងយន្តហោះ រថយន្ត រថភ្លើង ចុះម៉ូកកប៉ាល់ ។ល។ នោះអ្នកដែលចេះភាសាបរទេស ហើយត្រូវការរាក់ទាក់ទៅដោយមេត្រីនឹងអ្នកបរទេស

www.budinst.gov.kh www.elibraryofcambodia.org

នោះ ៗ   នឹងនិយាយភាសាបរទេសបានឥតមានទាស់ខ្ទងអ្វីឡើយ ។ ការនិយាយភាសាបរទេស ទៅកាន់អ្នកបរទេស ជាប្រយោជន៍ឲ្យយើងបានចាំពាក្យសំដីនៃភាសាដទៃនោះផង ចាំបែបផែន ទម្លាប់ដែលគេនិយាយនោះផង ។

*

*   *

## និយាយបំអកឡកឡឺយ

ដំណើរនិយាយបំអកឡកឡឺយឲ្យគេឯងពល់គ្នា ឬចំពោះអ្នកឯណាទីមួយ នៅក្នុងទីប្រជុំ ១ នោះ គប្បីប្រយ័ត្នឲ្យមែនទែន ខ្លាចទៅជាកហេតុបង្កើតជាជំលោះឈ្លោះជេរពោលពេលពត់គ្នា ជួនកាលបណ្ដាលដល់ទៅវាយតប់ ចាក់ឆាក់កាប់សម្លាប់គ្នាក៏សឹងមាន ៗ ពាក្យនិយាយបំអកនេះកុំថាឡើយតែអ្នកដែលមិនស្និទ្ធស្នាល សូម្បីតែមិត្រដែលជិតដិតចិត្ត ១ ថ្លើម ១ ផងគ្នា នោះការនិយាយលេងជាពាក្យបំអកក៏ត្រូវតែរាំងមុខក្រោយជាដរាប កុំឲ្យជ្រុលជ្រួសជ្រួលហួសពាល់តែពាស់គ្នាបាន ព្រោះពាក្យបំអករមែងធ្វើឲ្យគេអៀនអន់ស្រពន់ចិត្ត ខ្លាសមុខអ្នកដែលនៅទីប្រជុំនោះផង ៗ

*

*   *

www.budinst.gov.kh    www.elibraryofcambodia.org

# និយាយបន្ទោស

នឹង

# រំលឹកដាស់តឿន

ក្នុងសង្គមនីមួយ ៗ ឬគ្រួសារ ឬក្រសួង ឬក្រុម ឬផ្នែក ដែលចាត់ជាពួកគណៈនោះ បណ្ដាសាច់សាលោហិតក្ដី បុគ្គលិកក្ដី សហការីក្ដី សមាជិកក្ដី សិស្សានុសិស្សក្ដី... ។ល។ ដែលរួមសុខ-ទុក្ខជាមួយ រួមការងារជាមួយគ្នា រួមគំនិតកំឡាំងជាមួយគ្នា... ។ល។ តែងមានដំណើរខ្វែងគំនិតគ្នាក៏មាន ហើយឲ្យជាហេតុមិនបានស្រុះស្រួលព្រមព្រៀងគ្នា ។ ខ្លះជ្រុលហួសដល់ទៅសម្ដែងអាកប្បកិរិយាមិនល្អមើល ខ្លះពោលនូវវាចាមិនពីរោះដាក់គ្នាទៅវិញទៅមក ។ តែក្នុងសង្គមក្ដី ក្នុងពួកគណៈក្ដី រមែងមានមេ មានបា គ្រូអាចារ្យ មាតាបិតា អធិបតី សំរាប់និយាយស្ដី ដឹកនាំអ្នកដែលជាសហការី ជាកូនជាចៅនៅក្រោមបង្គាប់ ។

ដូច្នេះបើជនណាមួយប្រព្រឹត្តខុសច្បាប់ទម្លាប់ទំនៀម ឬវិន័យសិក្ខា នោះលោកអ្នកដែលជាប្រធាន ជាសហការីផងគ្នា អាចនឹងនិយាយរំលឹកដាស់តឿនគ្នាបាន តែគប្បីហៅគេយកមកនៅទីមួយស្ងាត់តែពីរនាក់ សឹមនិយាយប្រាប់នូវទោសដែលខុស ប្រាប់នូវពាក្យសំដីដែលខ្លួនបានពោលលើសលោះមិនសមគួរ ប្រាប់នូវកិរិយាដែលខ្លួនបានប្រព្រឹត្តកន្លង

www.budinst.gov.kh www.elibraryofcambodia.org

ទៅហើយជាការមិនគួរគប្បី ។ ការរំលឹកដាស់តឿនម្ដងជាពីរដងហើយ អ្នកនោះពុំយកជំបូន្មានតាម នោះត្រូវលែលកឈប់និយាយស្ដី ឬឈប់រាប់អានជាសហការី ក្នុងពួកក្នុងគណៈ ។ តែបើជាអ្នករាជការវិញ លោកតែងធ្វើទណ្ឌកម្មតាមក្រឹតច្បាប់ដែលតាំងទុកមក ។

ចំណែកមាតា បិតា នឹងបុត្រ - ធីតាដែលនៅតូច ៗ ការបន្ទោសស្ដីប្រដៅពុំចាំបាច់រកទីស្ងាត់ទេ ឃើញទាស់ខុសត្រង់ណា ត្រូវកុំបណ្ដែតបណ្ដោយឲ្យខុសសិនចុះ ព្រោះថាក្មេងពុំទាន់ដឹងខុស - ត្រូវយ៉ាងនេះត្រឡប់ទៅជាពុំប្រសើរវិញទេ ។ ដ្បិតធម្មជាតិក្មេងតែបណ្ដោយឲ្យឡើងដៃនោះកាន់តែកើតកើនឥតល្បប ឥតសណ្ដាប់ធ្នាប់ខូចបុកពាអស់ ម្ល៉ោះហើយទម្លាប់នោះផុះជាប់ក្នុងសន្ដានចិត្ត ដល់ចាស់ទៅក៏នៅតែមិនដឹងខុសត្រូវដូចពីក្មេងដរាបមក ។

តែចំណែកមនុស្សដែលសន្មតថាជាចាស់បានការហើយ គឺមាតាបិតា ឲ្យមានភរិយា ស្វាមីហើយ ឬរាជការរើសយកទៅតាំងជាខ្ញុំរាជការ ១ រូបហើយ នោះការស្ដីបន្ទោសដាស់តឿនរបស់មាតាបិតា គ្រូអាចារ្យ ចៅហ្វាយនាយ ប្រធាន អធិបតី គប្បីធ្វើដោយសម្ងាត់ជាដរាបទើបប្រសើរ ។

www.budinst.gov.kh www.elibraryofcambodia.org

## និយាយកុហក

បុរាណលោកចងជាពាក្យប្រដៅទុកថា "ពាក្យច្រើនកួតទាញកគ្នា" នេះបានសេចក្តីថា អ្នកឯណាច្រើនប្រើពាក្យសំដីនិយាយកួតកអ្នក នោះទោះជាមានយសស័ក្តិខ្ពង់ខ្ពស់ក្តី មានជាតិ-ត្រកូលខ្ពង់ខ្ពស់ក្តី ដោយសារប្រើសំដីវៀចវេរ មិនត្រង់ត្រឹមត្រូវ ត្រឡប់ទៅជាមនុស្សថោកទាបទៅវិញ ។ បើគេស្គាល់ច្បាស់ថាជាមនុស្សច្រើននិយាយកុហកបញ្ឆោតគេហើយ ទោះខ្លួននិយាយត្រង់ក៏គេមិនជឿ ខ្លះគេមិនទាំងស្តាប់ផង ខ្លះទៀតគេក្រោកចោលមិននិយាយផង ។ យ៉ាងនេះហើយទើបលោកឲ្យឈ្មោះថា "ពាក្យច្រើនកួត ទាញកគ្នា" ។

ឯការនិយាយកុហកនេះ បើកាលណាអ្នកចាំងពួងដេញគំនិតទាន់ នោះក៏នឹងកើតសេចក្តីអៀនខ្មាសចំពោះមុខមហាជនក្រៃលែងទៅទៀត ។

*

* *

## និយាយកាត់

ដំណើរនិយាយកាត់គេឯងកល់គ្នា ដែលគេកំពុងប្រស្រ័យគ្នានូវការផ្សេងៗ ជាកិរិយាមិនសមគួរទេ គេអាចចាប់ហេតុ ឬ សំគាល់ក្នុងចិត្តគេបានថា យើងជាមនុស្សព្រហើន មិនចេះគោរពកិច្ចក្នុងការនិយាយស្តី ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ១ — បើយើងមានការពិគ្រោះជជែករកខុសត្រូវជាមួយនឹងមិត្តម្នាក់ឬជនណាមួយ នោះគប្បីទុកពេលចែកគ្នានិយាយបរិយាយម្ដងម្នាក់ មិនត្រូវកាត់សេចក្ដីដែលគេកំពុងអធិប្បាយឲ្យដាច់ទេ ៗ តែបើយើងត្រូវការកាត់ដើម្បីកុំឲ្យវែងសេចក្ដី នោះយើងគប្បីសូមទោសគ្នាជាមុនថា "ខ្ញុំសូមទោស សូមកាត់សេចក្ដីលោកអ្នក ព្រោះរឿងនេះដូច្នេះវិញទេ ៗ"

២.— គេកំពុងនិយាយគ្នា យើងមានការជាប្រញាប់ត្រូវប្រាប់អ្នកមួយក្នុងចំណោមនោះ ៗ យើងត្រូវសុំទោសអ្នកទាំងឡាយជាមុនថា "ខ្ញុំសូមទោសអស់លោក-អ្នក សូមនិយាយបន្តិច ទឹងអស់លោកនោះ អ្នកនោះ ៗ រួចយើងនាំគ្នាចេញពីចំណោមគេបករកទី ១ ទៀតនិយាយគ្នាយ៉ាងនេះទើបសមគួរ ៗ

៣.— បើចៅហ្វាយនាយ គ្រូអាចារ្យលោកនិយាយគ្នាអំពីការអ្វីមួយ ហើយដោយមានលោកខ្លះអធិប្បាយដោយកាន់ច្រឡំ ។ យើងក៏នៅ ៗ ទីនោះដែរ យើងបានដឹងជាក់ប្រាកដនូវរឿងនោះ ។ បើឥតលោកណាមួយសួរដណ្ដឹងមកទេ យើងជាអ្នកតូចកុំគប្បីឆ្លើយកាត់ទៅទេ ព្រោះការឆ្លើយកាត់ឥតមានគេសួរ ហាក់ដូចជាមើលងាយលោកអ្នកនិយាយដោយកាន់ច្រឡំនោះ ឬហាក់ដូចនិយាយដើម្បីផ្ចាញ់ផ្ចាល់ ៗ ដូច្នេះការនិយាយ

www.budinst.gov.kh www.elibraryofcambodia.org

កាន់តែជាអំពើមិនល្អ មិនសមគួរ មិនគោរពដល់គេឯងដែលយើងនិយាយ

កាត់ទៅនោះ ។

*
* *

## និយាយនៅពេលបរិភោគអាហារ

យើងកល់គ្នាមានបំណងដូច ១ គ្នាចាំងអស់ នៅកល់ពេលដែលបរិ-

ភោគអាហារគឺប្រាថ្នាចង់បានតែម្ហូបដែលមានរសជាតិឆ្ញាញ់ពិសា ប្រាថ្នា

ទៀតត្រូវមាត់ទើបសុខចិត្តសុខកាយសប្បាយរីករាយ ។

តែប៉ុន្តែ បើបានអាហារឆ្ញាញ់ពិសាយ៉ាងណាក៏ដោយ យើងនឹង

អាស្រ័យក៏ពុំបាន លេបពុំរួច រសជាតិអាហារនោះត្រឡប់ជាមិនឆ្ញាញ់

មិនត្រូវមាត់ទៅវិញ ។ ទោសនេះបណ្តាលមកពីហេតុផ្សេង ១ គឺ៖

១.— កើតឡើងអំពីយើងមានជម្ងឺនៅក្នុងខ្លួន ។

២.— កើតឡើងអំពីទោសៈក្រោធខឹងមុនពេលបរិភោគអាហារ ឬ

នៅពេលកំពុងបរិភោគ ។

៣.— កើតឡើងអំពីទុក្ខសោកសង្រេងសង្រៃ ។

៤.— កើតឡើងអំពីសេចក្តីតោមនស្សព្រួយចង្អៀតចិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

៥.- កើតឡើងពីសេចក្ដីខ្ពើមរអើមដោយឃើញរបស់ស្មោកគ្រោក ឬដោយធុំក្លិនអសោចិ៍ស្អុយស្អេះស្អាបដែលមិនជាទីគាប់ចិត្ត ឬដោយមិនធ្លាប់ធន់ទ្រាំនឹងវត្ថុក្រខ្វក់ទោះសោះ ។

ដូច្នេះនៅពេលបរិភោគអាហារ ដែលរួមភាជន៍រួមតុជាមួយគ្នាច្រើនក្នុងក្រុមគ្រួសារនៅក្នុងទីប្រជុំមិត្តភក្តិ នៅក្នុងទីប្រជុំញាតិសាច់សាលោហិតទៀតនិងលោកក្ដី ... ។ល។

យើងគប្បីចៀសវាងពោលពាក្យដែលធ្វើឲ្យគេឯងលេបអាហារមិនរួច ដោយសំដីរបស់យើងមិនពីរោះបង្កើតឡើងនូវទោសដូចសំដែងមកហើយខាងលើ ។

គឺ មិនត្រូវនិយាយនូវពាក្យ៖

១.- ចាក់ដោតឲ្យគេក្រោធខឹង ។

២.- រំលឹកអំពីទុក្ខសោកសង្រេងសង្រៃផ្សេងៗ ។

៣.- សំដីអសុរោះធ្វើឲ្យគេទោមនស្សបង្អៀតចិត្ត ។

៤.- ដំណាលអំពីវត្ថុក្រខ្វក់ដែលគួរខ្ពើម ដូចជាសាកសពស្អុយលាមក ... ។ល។

www.budinst.gov.kh www.elibraryofcambodia.org

យើងគប្បីនិយាយសំណេះសំណាលអំពីកាលដែលយើងសប្បាយរីករាយ ឬ ពីរឿងត្លុកកំប្លែងលេងប្រែឡែងដោយពាក្យក្រមាច់ទៅមកកាន់គ្នា... ដើម្បីបំភ្លេចនូវសេចក្ដីព្រួយតែរៀងខ្លួន ម្ល៉ោះសមនឹងបរិភោគក៏បានច្រើន ពោះជាអាហារពុំសូវឆ្ងាញ់ពីសារក៏គង់បានគ្រាន់បើជាជាងលេបទាំងទុក្ខទោមនស្សព្រាស់ចិត្តនឹងគេ ឬដោយខ្ទើមរអើម ៗ

*
* *

(នៅមានភាគទី ២ តទៅទៀត)

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីរឿង


| | | | |
|---|---|---|---|
| ១ — | បុរាណភាសិត | ទំព័រទី | ៣ |
| ២ — | ដំណេក | " | ៣ |
| ៣ — | ដេក (ឥរិយាបថទី ១) | " | ៥ |
| ៤ — | អង្គុយ (ឥរិយាបថទី ២) | " | ៧ |
| ៥ — | ទីបង្គុយរោងវេរការ (ព្រះសង្ឃ) | " | ៨ |
| ៦ — | ទីបង្គុយ (គ្រហស្ថ - ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ) | " | ១១ |
| ៧ — | ទីបង្គុយ (តាមអារ្យធម៌អឺរ៉ុប) | " | ១៣ |
| ៨ — | ទីបង្គុយ (តាមទំនៀមពីបុរាណកាល) | " | ១៣ |
| ៩ — | ទីបង្គុយ (ក្មេង) | " | ១៥ |
| ១០ — | លក្ខណៈអង្គុយនៅមុខអ្នកធំ | " | ១៧ |
| ១១ — | អង្គុយលើកៅអី | " | ២០ |
| ១២ — | អង្គុយគោរពចំពោះស្ត្រីនិងមនុស្សចាស់ | " | ២១ |
| ១៣ — | អង្គុយគោរពចំពោះព្រះសង្ឃ | " | ២២ |
| ១៤ — | អង្គុយក្នុងរថ | " | ២៣ |
| ១៥ — | ឈរ (ឥរិយាបថទី ៣) | " | ២៥ |
| ១៦ — | ឈរនៅទីប្រជុំ | " | ២៦ |
| ១៧ — | ឈរ ជិតអ្នកអង្គុយ | " | ២៧ |
| ១៨ — | ក្រោកឈរ | " | ២៨ |
| ១៩ — | ឈរនៅក្នុងកន្លែងធ្វើការ | " | ២៩ |
| ២០ — | ឈរនៅទីជាឆា | " | ២៩ |
| ២១ — | ឈរលេង | " | ៣០ |
| ២២ — | ឈរគោរពទង់ជាតិ - និងភ្លេងជាតិ | " | ៣១ |
| ២៣ — | ដើរ (ឥរិយាបថទី ៤) | " | ៣២ |
| ២៤ — | ដើរ ក្នុងក្បួនហែ | " | ៣២ |


www.budinst.gov.kh www.elibraryofcambodia.org

២៥ — ដើរជាមួយព្រះសង្ឃ . . . . . . . . . . . . . . . . . . . ទំព័រទី ៣៣

២៦ — ដើរកាត់ហ្វូង . . . . . . . . . . . . . . . . . . . " ៣៥

២៧ — កិរិយាដើរ . . . . . . . . . . . . . . . . . . . " ៣៥

២៨ — ដំណើរដើរកន្លង . . . . . . . . . . . . . . . . . . . " ៣៧

២៩ — បង្វិលខ្លួន . . . . . . . . . . . . . . . . . . . " ៣៨

៣០ — ក្អក - កណ្តាស . . . . . . . . . . . . . . . . . . . " ៤០

៣១ — ខាក - ស្តោះ . . . . . . . . . . . . . . . . . . . " ៤០

៣២ — ស្ងាប . . . . . . . . . . . . . . . . . . . " ៤២

៣៣ — បង្គុំ - សំពះ . . . . . . . . . . . . . . . . . . . " ៤៣

៣៤ — សំពះសួរ – នឹងសំពះលា . . . . . . . . . . . . . . . . . . . " ៤៦

៣៥ — លក្ខណៈសំពះ . . . . . . . . . . . . . . . . . . . " ៤៧

៣៦ — កិរិយាដែលសំពះ . . . . . . . . . . . . . . . . . . . " ៤៨

៣៧ — គំនាប់ងក់ក្បាលចាប់ដៃ . . . . . . . . . . . . . . . . . . . " ៤៩

៣៨ — ប្រគេន - ថ្វាយ - ជូន . . . . . . . . . . . . . . . . . . . " ៥២

៣៩ — ហុច . . . . . . . . . . . . . . . . . . . " ៥៣

៤០ — របស់ប្រគេនលោកសង្ឃ - ថ្វាយក្សត្រិយ៍ - ជូនបុព្វការីឬចៅហ្វាយ
នាយ ឬ ចាស់ព្រឹទ្ធាចារ្យ . . . . . . . . . . . . . . . . . . . " ៥៤

៤១ — និយាយ . . . . . . . . . . . . . . . . . . . " ៥៦

៤២ — របៀបនិយាយ . . . . . . . . . . . . . . . . . . . " ៥៧

៤៣ — និយាយក្នុងទីប្រជុំ . . . . . . . . . . . . . . . . . . . " ៦២

៤៤ — និយាយលេង . . . . . . . . . . . . . . . . . . . " ៦៦

៤៥ — និយាយខ្សឹប . . . . . . . . . . . . . . . . . . . " ៦៧

៤៦ — ត្រូវនិយាយខ្សឹប . . . . . . . . . . . . . . . . . . . " ៦៧

៤៧ — មិនត្រូវនិយាយខ្សឹប . . . . . . . . . . . . . . . . . . . " ៦៩

៤៨ — មិនត្រូវនិយាយភាសាដទៃ . . . . . . . . . . . . . . . . . . . " ៧០


www.budinst.gov.kh www.elibraryofcambodia.org

៤៩ – និយាយចំអក-ឡុកឡឺយ . . . . . . . . . . . . . . . . ទំព័រទី ៧១
៥០ – និយាយបន្ទោស-រំលឹកដាស់តឿន . . . . . . . . . . . " ៧២
៥១ – និយាយកុហក . . . . . . . . . . . . . . . . . . " ៧៤
៥២ – និយាយកាត់ . . . . . . . . . . . . . . . . . . " ៧៤
៥៣ – និយាយនៅពេលបរិភោគអាហារ . . . . . . . . . . . " ៧៦

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org